សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខគោលនយោបាយ៖ សសសក _______________

# គោលនយោបាយស្តីពីការប្រាស្រ័យទាក់ទង

*(ជួយដល់អ្នកដឹកនាំអ្នកស្ម័គ្រចិត្តឱ្យយល់អំពីដំណើរការ និងពិធីសារសម្រាប់ការនិយាយស្តីនៅក្នុងអង្គភាព)*

## គោលបំណងនៃគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទង

ក្នុងឱកាសខ្លះ មន្ត្រី សមាជិកក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ និងក្រុមអាចនឹងត្រូវបានស្នើសុំឱ្យសម្តែងមតិទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលមកលើវិជ្ជាជីវៈ។

គោលដៅមួយក្នុងចំណោមគោលដៅច្បាស់លាស់ផ្សេងៗទៀតរបស់អង្គភាព គឺការនិយាយតាងនាមឱ្យសមាជិកនៅពេលដែលសកម្មភាពនេះអាច គឺដើម្បីជាផលប្រយោជន៍ និងផ្តល់ជាអត្ថប្រយោជន៍ដល់សមាជិករបស់យើង។ យើងមានបំណងបញ្ជូននូវសារដែលត្រឹមត្រូវ និងមានភាពច្បាស់លាស់។

ការបង្ហាញអំពីទស្សនៈរបស់អង្គភាព ចំពោះបញ្ហាដែលពាក់ព័ន្ធជាមួយនឹងផលប្រយោជន៍របស់យើង គឺជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីសេវាកម្ម និងទំនាក់ទំនងសាធារណៈដែលមានអត្ថន័យ។ ប្រការនេះ អាចជាផ្នែកមួយដ៏មានប្រសិទ្ធភាព ក៏ប៉ុន្តែមានប្រសិទ្ធភាពតែនៅពេលដែលអនុវត្តក្នុងលក្ខណៈដែលមានរបៀបរៀបរយ មានសង្គតិភាពជាមួយនឹងគោលនយោបាយដែលបានចែងច្បាស់លាស់តែប៉ុណ្ណោះ។

គោលបំណងនៃសេចក្តីថ្លែងនេះ គឺដើម្បីបញ្ជាក់អំពីសិទ្ធិអំណាច និងទំនួលខុសត្រូវរបស់បុគ្គល ឬក្រុម ក្នុងការបញ្ចេញមតិ ខណៈពេលដែលពួកគាត់មានទំនាក់ទំនងផ្លូវការជាមួយនឹងអង្គភាព។

នៅក្នុងសេចក្តីថ្លែងនេះ មិនមានចំណុចណាមួយដែលមានបំណងធ្វើការដាក់កំហិតទៅលើ ឬរារាំងទំនាក់ទំនងធម្មតា ឬទំនាក់ទំនងជាប្រចាំរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ និងក្រុមឡើយ។

សេចក្តីថ្លែងនេះក៏មិនមានចេតនារារាំងបុគ្គលណាម្នាក់ក្នុងការបញ្ចេញ***ទស្សនៈផ្ទាល់ខ្លួន*** ឡើយ ក៏ប៉ុន្តែ អ្នកដែលមានតួនាទីនៅក្នុងថ្នាក់ដឹកនាំ ត្រូវតែយល់ដឹងអំពីឱកាសដែលទស្សនៈផ្ទាល់ខ្លួនរបស់ពួកគាត់អាចនឹងភាន់ច្រលំជាមួយនឹងទស្សនៈផ្លូវការរបស់ពួកគាត់។

## ការគិតគូរពិចារណា

ជាដំបូង ការផ្ទេរសិទ្ធិអំណាច និងទំនួលខុសត្រូវនឹងត្រូវប្រព្រឹត្តទៅដោយពាក់ព័ន្ធជាមួយនឹងក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ហើយបន្ទាប់មកពាក់ព័ន្ធជាមួយនឹងផ្នែកដទៃទៀត។ ក៏ប៉ុន្តែ មានការគិតគូរពិចារណាមូលដ្ឋានចំនួនពីរសម្រាប់ការផ្ទេរសិទ្ធិអំណាចទាំងអស់។

ទីមួយ រាល់សេចក្តីថ្លែងនានារបស់បុគ្គល ឬក្រុមណាមួយ គួរតែទទួលបានការសិក្សាស្វែងយល់ឱ្យបានច្បាស់ ទាញរកហេតុផល និងចងក្រងជាឯកសារទុកឱ្យបានត្រឹមត្រូវក្នុងស្ថានភាពដែលអាចអនុវត្តទៅបាន។ ទីពីរ ប្រសិនបើជាបញ្ហាដែលពាក់ព័ន្ធនឹងការចម្រូងចម្រាសធ្ងន់ធ្ងរនៅក្នុងវិជ្ជាជីវៈ បុគ្គល ឬក្រុមនោះគួរតែខិតខំស្វះស្វែងបង្ហាញអំពីចំណុចល្អ និងចំណុចមិនល្អរបស់សំណួរនេះ។ ប្រសិនបើពួកគេធ្វើសេចក្តីថ្លែងដោយមានការគាំទ្រពីមុខតំណែងណាមួយ ពួកគេត្រូវតែមានភាពច្បាស់លាស់ថាសេចក្តីថ្លែងនោះនឹងតំណាងឱ្យមតិផ្ទាល់ខ្លួនរបស់ពួកគេ មិនមែនជាមតិរបស់អង្គភាពឡើយ។

## ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ

ក្រុមប្រឹក្សាអាចធ្វើសេចក្តីថ្លែងការណ៍តាងនាមឱ្យអង្គភាពនៅពេលណាមួយក៏បាន។ គណៈកម្មាធិការប្រតិបត្តិអាចធ្វើ ឬផ្តល់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍តាងនាមឱ្យអង្គភាពបាននៅក្នុងស្ថានភាពបន្ទាន់ ឬក្នុងស្ថានភាពផ្សេងទៀតដែលមិនអាចរង់ចាំវិធានការពីក្រុមប្រឹក្សាបាន។

## ប្រធានសមាគម និងនាយកប្រតិបត្តិ

ប្រធានសមាគម និងនាយកប្រតិបត្តិ មានសិទ្ធិក្នុងការរៀបចំការឆ្លើយតបទៅកាន់បញ្ហាដែលតម្រូវឱ្យមានការឆ្លើយតបរហ័សតាមលក្ខណៈវិជ្ជាជីវៈ។ ទោះជាយ៉ាងណាក៏ដោយ ប្រធានសមាគម និងនាយកប្រតិបត្តិគួរតែខិតខំពិភាក្សាអំពីបញ្ហាជាមួយនឹងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិរាល់ពេលដែលអាចអនុវត្តទៅបាន។

## ប្រធានក្រុម

ប្រធានក្រុម ឬអ្នកដឹកនាំតាមខេត្ត មានសិទ្ធិក្នុងការរៀបចំការឆ្លើយតបទៅកាន់បញ្ហាដែលតម្រូវឱ្យមានការឆ្លើយតបរហ័សតាមលក្ខណៈវិជ្ជាជីវៈ។ ទោះជាយ៉ាងណាក៏ដោយ ប្រធានក្រុមគួរតែបញ្ជាក់អំពីការឆ្លើយតបនេះជាមួយនឹងប្រធានស្ថាប័នអាណាព្យាបាល និង/ឬ នាយកប្រតិបត្តិ។

### ប្រធានគណៈកម្មាធិការ និងបុគ្គលិក

ប្រធានគណៈកម្មាធិការ និងបុគ្គលិកអាចសម្តែងមតិតាងនាមឱ្យអង្គភាពបានលុះត្រាតែគោរពតាមគោលនយោបាយ ឬបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលតែប៉ុណ្ណោះ លើកលែងតែលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

- សេចក្តីថ្លែងការណ៍នេះត្រូវតែនៅក្នុងដែនសមត្ថកិច្ច និងដែនយុត្តាធិការបច្ចេកទេសរបស់បុគ្គលនោះ។
- ការរៀបចំសេចក្តីថ្លែងការណ៍នេះត្រូវបានសម្របសម្រួលជាមួយនឹងប្រធានសមាគម និង/ឬ នាយកប្រតិបត្តិ។
- សេចក្តីថ្លែងការណ៍បង្ហាញនូវមតិភាគច្រើននៃសមាជិករបស់គណៈកម្មាធិការ ដោយផ្អែកលើការយល់ដឹងរបស់ពួកគេចំពោះទស្សនៈទូទៅភាគច្រើននៃវិជ្ជាជីវៈ។
- សេចក្តីថ្លែងការណ៍បញ្ជាក់បានច្បាស់លាស់ថា មតិដែលបានបង្ហាញឡើង គឺគ្រាន់តែជាមតិរបស់គណៈកម្មាធិការតែប៉ុណ្ណោះ។
- សេចក្តីថ្លែងការណ៍លុបលើ/យល់ស្របជាមួយរាល់សេចក្តីថ្លែងការណ៍ទាំងអស់ ដែលបានធ្វើឡើងកាលពីមុនចំពោះបញ្ហាដូចគ្នា។

## ប្រការ ១២៖ មូលដ្ឋានសម្រាប់ការបណ្តេញចេញ

១២.១. សមាជិករបស់សមាគមសហគ្រិនស្ត្រីកម្ពុជា នឹងត្រូវបណ្តេញចេញក្នុងករណីដែលបានរំលោភបំពានលើ ឬល្មើសទៅនឹងលក្ខន្តិកៈ ឬប្រព្រឹត្តសកម្មភាពណាមួយដែលនាំឱ្យមានការខូចខាតដល់កិត្តិយសរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា។

ខ) សមាជិកណាម្នាក់ ដែលផ្សព្វផ្សាយអំពី**<u>ព័ត៌មានមិនពិតដែលនាំឱ្យខូចខាតដល់គុណតម្លៃរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ឬបញ្ចេញព័ត៌មានសម្ងាត់។</u>**

គ) សមាជិកណាម្នាក់**<u>ដែលបង្ហាញអត្តសញ្ញាណខ្លួនឯងថា បំពេញការងារតាងនាមឱ្យសមាគមសហគ្រិនស្ត្រីកម្ពុជា</u>** ដោយមិនមានការចាត់តាំងដោយក្រុមប្រឹក្សាភិបាល។

១២.២. សមាជិក ត្រូវមានសិទ្ធិក្នុងការ**<u>ស្នើសុំលាឈប់ពីសមាគមសហគ្រិនស្ត្រីកម្ពុជា</u>** តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ **<u>សុពលភាពនៃសមាជិកភាព ត្រូវតែផុតកំណត់ នៅពេលដែល</u>**

<u>មានការអនុម័តដោយក្រុមប្រឹក្សាភិបាលជាលាយលក្ខណ៍អក្សរនៅលើលិខិតលាយឈប់</u> នៅក្នុងកិច្ចប្រជុំដំបូងរបស់ខ្លួន ឬនៅពេលទទួលបានលិខិតលាយឈប់នោះ។

រៀបរៀងដោយ៖



លោកស្រី អូនី លូណា
ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៩

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

*លេខ៖ ០៩២/១៨ សសសក*

# គោលនយោបាយស្តីពីការប្រាស្រ័យទាក់ទង (ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន/ព័ត៌មានសាធារណៈ)

(ជួយឱ្យអ្នកដឹកនាំស្ម័គ្រចិត្តយល់ដឹងអំពីដំណើរការ និងពិធីការសម្រាប់ការនិយាយក្នុងនាមសមាគម)

## គោលបំណងនៃគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទង

មានឱកាសខ្លះ មន្ត្រី សមាជិកក្រុមប្រឹក្សា គណៈកម្មាធិការ និងសាខា (ប្រសិនបើមាន) ត្រូវបានស្នើឱ្យបញ្ចេញមតិយោបល់ចំពោះរឿងផ្សេងៗដោយផ្ទាល់ ឬដោយប្រយោល ដែលមានឥទ្ធិពលដល់វិជ្ជាជីវៈការងារ។

គោលដៅច្បាស់លាស់មួយក្នុងចំណោមទស្សនៈរបស់សមាគម ចំពោះរឿងត្រឹមត្រូវចំពោះប្រយោជន៍ដល់យើងគ្រប់គ្នា គឺជាផ្នែកសំខាន់មួយនៃកម្មវិធីសេវា និងទំនាក់ទំនងសាធារណៈដ៏មានអត្ថន័យនានា។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំអាចជាផ្នែកដ៏មានប្រសិទ្ធភាពមួយបាន លុះត្រាតែបានបំពេញការងារប្រកបដោយរបៀបរៀបរយ ស្របតាមគោលនយោបាយមួយដែលបានប្រកាសយ៉ាងច្បាស់លាស់ប៉ុណ្ណោះ។

ឯកសារនេះមានគោលបំណងបំភ្លឺបញ្ជាក់អំពីអំណាច និងទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ឬក្រុមនីមួយៗ កាលណាពួកគេមានមុខងារផ្លូវការណាមួយជាមួយសមាគមនៅក្នុងការបញ្ចេញមតិយោបល់អ្វីមួយ។
គ្មានខ្លឹមសារណាមួយនៅក្នុងឯកសារគោលនយោបាយនេះមានបំណងរឹតត្បិត ឬរារាំងការឆ្លើយឆ្លងជាធម្មតា ឬជាប្រចាំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការ និងសាខាឡើយ ហើយគោលនយោបាយនេះក៏គ្មានបំណងរឹតត្បិតបុគ្គលម្នាក់ៗនៅក្នុងការបញ្ចេញទស្សនៈផ្ទាល់ខ្លួនរបស់ខ្លួននោះដែរ។ ក៏ប៉ុន្តែ អ្នកដែលកាន់មុខតំណែងដឹកនាំត្រូវទទួលស្គាល់នូវភាពដែលទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេអាចច្រឡំជាមួយនឹងទស្សនៈផ្លូវការរបស់ខ្លួន។

### ចំណុចត្រិះរិះពិចារណា

ប្រតិភូកម្មសិទ្ធិអំណាច និងទំនួលខុសត្រូវធ្វើឡើង ទីមួយ ទាក់ទងនឹងក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ និងទីពីរ ទាក់ទងនឹងអ្នកដទៃទៀត។ ប៉ុន្តែ មានការត្រិះរិះពិចារណាជាមូលដ្ឋានពីរសម្រាប់រឿងទាំងអស់នេះ។

ទីមួយ រាល់សេចក្តីថ្លែងការណ៍ដោយបុគ្គល ឬក្រុមណាមួយ ត្រូវសិក្សា ដេញដោលហេតុផល និងតម្កល់ទុកជាឯកសារឱ្យបានត្រឹមត្រូវ តាមការដែលអាចធ្វើទៅបាន។ ទីពីរ ប្រសិនបើរឿងនោះពាក់ព័ន្ធនឹងបញ្ហាចម្រូងចម្រាសខ្លាំងក្នុងវិជ្ជាជីវៈ បុគ្គល ឬក្រុមនោះ ត្រូវខំប្រឹងបង្ហាញនូវមតិស្រប និងមតិផ្ទុយទៅលើបញ្ហាទាំងនោះ។ ប្រសិនបើពួកគេចេញសេចក្តីថ្លែងការណ៍គាំទ្រជំហរជាក់លាក់ណាមួយ ពួកគេត្រូវប្រាកដថា សេចក្តីថ្លែងការណ៍នោះ គឺជាមតិយោបល់ផ្ទាល់ខ្លួនរបស់ពួកគេ ពោលគឺមិនតំណាងឱ្យមតិយោបល់របស់សមាគមនោះទេ។

### ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ

ក្រុមប្រឹក្សាអាចចេញសេចក្តីថ្លែងការណ៍តាងនាមសមាគមបានគ្រប់ពេលវេលាទាំងអស់។

គណៈកម្មាធិការប្រតិបត្តិអាចចេញ ឬអនុញ្ញាតឱ្យចេញសេចក្តីថ្លែងការណ៍តាងនាមសមាគមបាននៅក្នុងពេលវេលាចាំបាច់ ឬនៅក្នុងលក្ខខណ្ឌផ្សេងទៀតដែលពុំមានភាពសមស្របនៅក្នុងការរង់ចាំចំណាត់ការរបស់ក្រុមប្រឹក្សា។

### ប្រធាន និងនាយកប្រតិបត្តិ

ប្រធាន និងនាយកប្រតិបត្តិ រួមគ្នាមានសិទ្ធិអំណាចក្នុងការរៀបចំចម្លើយតបនឹងរឿងផ្សេងៗដែលត្រូវការការឆ្លើយតបឆាប់រហ័សតាមវិជ្ជាជីវៈការងារ។ ក៏ប៉ុន្តែ ប្រធាន និងនាយកប្រតិបត្តិ ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើការពិភាក្សាលើរឿងនោះជាមួយសមាជិកគណៈកម្មាធិការប្រតិបត្តិតាមលទ្ធភាពដែលអាចធ្វើទៅបាន។

### ប្រធានសាខា (ប្រសិនបើមាន)

ប្រធានសាខាមានសិទ្ធិអំណាចរៀបចំចម្លើយតបទៅនឹងបញ្ហាផ្សេងៗ ដែលត្រូវការការឆ្លើយតបជាបន្ទាន់ទៅតាមវិជ្ជាជីវៈការងារ ប៉ុន្តែប្រធានសាខាគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវចម្លើយទាំងនេះជាមួយប្រធានអង្គភាព និង/ឬ នាយកប្រតិបត្តិរបស់សមាគមមេ។

### ប្រធានគណៈកម្មាធិការ និងសមាជិកបុគ្គលិក

- ប្រធានគណៈកម្មាធិការ និងសមាជិកបុគ្គលិកអាចនិយាយតាងនាមសមាគមបានសម្រាប់តែកិច្ចការពាក់ព័ន្ធនឹងគោលនយោបាយ ឬកិច្ចការដែលត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាភិបាលរួចហើយប៉ុណ្ណោះ លើកលែងតែនៅពេលណាដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ➢ សេចក្តីថ្លែងការណ៍ត្រូវស្ថិតក្រោមសមត្ថភាពបច្ចេកទេស និងក្នុងដែនសមត្ថកិច្ចរបស់បុគ្គលម្នាក់ៗ។
- ➢ ការរៀបចំសេចក្តីថ្លែងការណ៍ត្រូវបានសម្របសម្រួលជាមួយប្រធាន និង/ឬ នាយកប្រតិបត្តិ។
- ➢ សេចក្តីថ្លែងការណ៍បញ្ជាក់យ៉ាងច្បាស់ថា មតិយោបល់ដែលបានបញ្ចេញ គឺគ្រាន់តែជាមតិយោបល់របស់គណៈកម្មាធិការតែប៉ុណ្ណោះ។
- ➢ សេចក្តីថ្លែងការណ៍ដែលលុបចោលនូវរាល់សេចក្តីថ្លែងការណ៍ពីមុនៗស្តីពីកម្មវត្ថុដដែល។

## ពិធីសារនៃការប្រាស្រ័យទាក់ទង (គំរូ)

សមាគមចង់ថែរក្សាទំនាក់ទំនងការងារវិជ្ជមានជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ទំនាក់ទំនងនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបន្តពង្រឹងសមិទ្ធផល និងគោលដៅសម្រាប់វិជ្ជាជីវៈ និងការរៀបចំសមាជិករបស់យើង។

តាមដែលអាចធ្វើទៅបាន តួនាទីអ្នកនាំពាក្យត្រូវរ៉ាប់រងដោយបុគ្គលម្នាក់ដែលត្រូវបានចាត់តាំង។ ជាធម្មតា គឺប្រធានក្រុមប្រឹក្សាភិបាលជាប់ឆ្នោត ឬប្រធាន។ គាត់ ឬនាង អាចធ្វើប្រតិភូកម្មអំណាចជូនបុគ្គលបង្គោល ដូចជានាយកប្រតិបត្តិ ឬអគ្គលេខាធិការជាដើម។

យើងសូមឱ្យអ្នកគោរពតាមលំដាប់អំណាច និងឋានានុក្រម ក្នុងករណីមានមន្ទិលទាក់ទងនឹងការប្រាស្រ័យទាក់ទងផ្លូវការណាមួយ។

## អំណាចស្តែងខាងក្រៅ

ដោយសារអ្នកកាន់មុខតំណែងថ្នាក់ដឹកនាំស្ម័គ្រចិត្ត (ក្រុមប្រឹក្សា គណៈកម្មាធិការ សាខា ។ល។) មិនថាអ្នកទំនាក់ទំនងនៅទីណាក្តី ជាលាយលក្ខណ៍អក្សរក្តី ឬដោយផ្ទាល់មាត់ក្តី គេនឹងកត់សម្គាល់ថា អ្នកកំពុងនិយាយក្នុងនាមសមាគម មិនមែនក្នុងនាមខ្លួនអ្នកផ្ទាល់នោះទេ។

ប្រសិនបើអ្នកត្រូវបានស្នើឱ្យបញ្ចេញមតិយោបល់ជាសាធារណៈ ឬនៅលើប្រព័ន្ធផ្សព្វផ្សាយយ៉ាងទូលំទូលាយ រឿងទីមួយដែលត្រូវធ្វើ គឺត្រូវស្នើសុំឱ្យតំណាងប្រព័ន្ធផ្សព្វផ្សាយជួបជាមួយបុគ្គលផ្លូវការម្នាក់របស់សមាគមយើង។ ប្រសិនបើពួកគេចង់បានសេចក្តីអធិប្បាយពីអ្នក សូមពិចារណាប្រើវិធីនិយាយតាមរបៀបរបស់ខ្លួនក្នុងន័យថា៖ “ខ្ញុំមិនអាចនិយាយក្នុងនាមសមាគមបានទេ ប៉ុន្តែប្រសិនបើអ្នកចង់បានមតិយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំអាចឆ្លើយបាន។”

## ផ្នែកមានសុវត្ថិភាពក្នុងការនិយាយ

ផ្នែកមានសុវត្ថិភាពក្នុងការនិយាយសម្រាប់ចាប់ផ្តើមកិច្ចសម្ភាសន៍ ត្រូវផ្តោតលើការថ្លែងជាផ្លូវការអំពីសមាគម។ សូមមើលសារតាសមាគមដែលមានចំណុចដូចខាងក្រោម៖

(១) ពាក្យស្លោករបស់យើង ប្រវត្តិត្រួសៗ សុន្ទរកថាថ្លែងជាផ្លូវការ
(២) បេសកកម្ម និងចក្ខុវិស័យរបស់យើង
(៣) គោលបំណង និងវត្ថុបំណងរបស់យើង
(៤) គុណតម្លៃស្នូលរបស់យើង
(៥) គោលដៅយុទ្ធសាស្ត្ររបស់យើង
(៦) ដំណោះស្រាយដែលយើងកំពុងប្រើប្រាស់ និងរបៀបអនុវត្តសកម្មភាពរបស់យើង

**ការត្រៀមរៀបចំ**

- ប្រសិនបើអ្នកត្រូវបានអញ្ជើញឱ្យចូលរួមក្នុងបទសម្ភាសន៍មួយ សូមពិចារណាលើចំណុចគន្លឹះទាំងនេះ៖
- ហៅបុគ្គលិកមកជួយប្រមូលធនធាន និងទិន្នន័យ
- ស្រាវជ្រាវរកអ្នកដែលនឹងសម្ភាសន៍អ្នក ស្វែងយល់ពីរបៀបរបបរបស់ពួកគាត់ និងអ្វីដែលពួកគាត់ចង់ដឹង
- កំណត់គោលដៅរបស់អ្នកនៅក្នុងបទសម្ភាសន៍ លទ្ធផលដែលអ្នកចង់បាន
- ធ្វើកម្រងសំណួរដែលអាចនឹងចោទសួរ និងសាកល្បងឆ្លើយសំណួរទាំងនោះ
- មានយ៉ាងតិច 2 ឬ 3 ចំណុច ដែលអ្នកចង់ផ្តល់ជូន

រៀបរៀងដោយ៖



អ្នកស្រី អូនី លូណា
ថ្ងៃទី31 ខែកក្កដា ឆ្នាំ2018

អនុម័តដោយមានការអនុញ្ញាត 9-10
ឯកសារ គំរូគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទង ជាទម្រង់ .Doc
លោក Bob Harris

CWEA

សមាគមសហគ្រិនស្ត្រីកម្ពុជា

CAMBODIA WOMEN ENTREPRENEURS ASSOCIATION

# ផែនការយុទ្ធសាស្ត្រ
# ឆ្នាំ២០២០ - ២០២៣

## "ពួកយើងធ្វើដំណើរឆ្ពោះទៅមុខ"


បច្ចុប្បន្នភាពដោយ៖ លោកស្រី អូនី លូណា

នាយិកាប្រតិបត្តិ

សមាគមសហគ្រិនស្ត្រីកម្ពុជា

# មាតិកា

ព័ត៌មានទូទៅរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា........................................១៨
សេចក្តីផ្តើម........................................២០
ផ្នែកទី ១៖ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូលរបស់យើង........................................២២
ផ្នែកទី ២ - អាទិភាពតំបន់យុទ្ធសាស្ត្រ/........................................២៤
ផ្នែកទី ៣៖ ការរៀបចំផែនការយុទ្ធសាស្ត្រ........................................៣០
អាទិភាពយុទ្ធសាស្ត្រទី១ ការតស៊ូមតិការបញ្ចុះបញ្ចូល/........................................៣០
អាទិភាពយុទ្ធសាស្ត្រទី ២៖ ការអភិវឌ្ឍអាជីវកម្ម........................................៣៨
អនុផ្នែកទី១ ការពង្រឹងសមត្ថភាព ការបណ្តុះបណ្តាល /........................................៣៨
អនុផ្នែកទី២៖ ការបង្កើតបណ្តាញអាជីវកម្ម........................................ ៤១
អនុផ្នែកទី៣៖ គណៈកម្មាធិការកម្មវិធី និងនវានុវត្តន៍ទីផ្សារ........................................ ៤២
អាទិភាពយុទ្ធសាស្ត្រទី ៣៖ ការអភិវឌ្ឍអង្គភាព........................................ ៤៥
អនុផ្នែកទី១៖ សមាជិកភាព........................................ ៤៥
អនុផ្នែកទី ២៖ ការពង្រីកអង្គភាព........................................ ៤៧
អាទិភាពយុទ្ធសាស្ត្រទី ៤៖ ការប្រាស្រ័យទាក់ទង និងទីផ្សារ ការ / ទំនាក់ទំនងសាធារណៈ / ផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ........................................ ៤៩
ឧបសម្ព័ន្ធ ១ អង្គការលេខសមាគមសហគ្រិនស្ត្រីកម្ពុជា........................................ ៥៦

# ព័ត៌មានទូទៅរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា

## ១. អង្គភាពរបស់យើង

សមាគមសហគ្រិនស្ត្រីកម្ពុជា

## ២. ប្រវត្តិរបស់សមាគម

សមាគមសហគ្រិនស្ត្រីកម្ពុជា (ស.ស.ស.ក) បានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១១ ហើយត្រូវបានបើកដំណើរការ និងសម្ពោធជាសាធារណៈនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១២។ សមាគមសហគ្រិនស្ត្រីកម្ពុជាមានការរីកចម្រើនចាប់តាំងពីសមាជិក ១៥ នាក់ រហូតដល់មានសមាជិកប្រមាណជា ៦០០++ នាក់គិតត្រឹមឆ្នាំ២០២០ នេះ។

## ៣. រចនាសម្ព័ន្ធអភិបាលកិច្ចរបស់សមាគម

សមាគមសហគ្រិនស្ត្រីកម្ពុជា គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាពនៃសហគ្រិនស្ត្រីល្បីល្បាញមកពីវិស័យផ្សេងៗគ្នាជាច្រើន។ សមាជិកក្រុមប្រឹក្សាពាំនាំមកនូវជំនាញ និងបទពិសោធន៍ផ្សេងៗជាច្រើននៅក្នុងការផ្តល់ជូននូវជំនួយបច្ចេកទេស និងការអភិវឌ្ឍអង្គភាពនៅក្នុងវិស័យធុរកិច្ច។ សមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាត។ ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់គោលនយោបាយ និងគោលដៅទាំងមូលរបស់សមាគម ព្រមទាំងចាត់ចែងទំនួលខុសត្រូវនានានៅក្នុងប្រតិបត្តិការប្រចាំថ្ងៃទៅឱ្យបុគ្គលិក និងគណៈកម្មាធិការ។ ក្រុមប្រឹក្សាភិបាលជាអ្នកធានាក្នុងការសម្រេចឱ្យបាននូវគោលដៅ និងចក្ខុវិស័យរបស់សមាគម។ ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសមាគមដែលដឹកនាំសមាគមសហគ្រិនស្ត្រីកម្ពុជាទាំងស្រុង។

## ៤. ព័ត៌មានទំនាក់ទំនងរបស់សមាគម

អាសយដ្ឋាន៖ បន្ទប់លេខ ៤៨៦ ជាន់ទីបួន អគារ H មជ្ឈមណ្ឌលភ្នំពេញ ផ្លូវសម្តេចសុធារស កែងមហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

លេខទូរសព្ទ៖ (+៨៥៥) ២៣ ២២៤ ៣៨៦

អ៊ីមែល៖ info@cweacambodia.org

វេបសាយត៍៖www.cweacambodia.org

## ៥. ក្រុមប្រឹក្សាភិបាលរបស់សមាគម ខែមីនា ឆ្នាំ២០១៨ ដល់ ខែមីនា ឆ្នាំ២០២១ (អាណត្តិ ៣ ឆ្នាំ)

| | | | |
|---|---|---|---|
| លោកជំទាវ វេជ្ជបណ្ឌិត អេង លីគង់ | ប្រធាន | ០១២ ១២៨ ២០០ ៨១ | lykuong_mcdc@yahoo.com |

| | | | |
|---|---|---|---|
| ឧកញ៉ា ស្រ៊ាត មុំសុភា | អនុប្រធានផ្នែកកិច្ចការខាងក្រៅ | ០៧៧ ៩៥៦ ៨៨៨ | sophear@sophiyacorp.com |
| លោកជំទាវ គង់ សូរីតា | អនុប្រធានផ្នែកកិច្ចការផ្ទៃក្នុង | ០១៥ ៩៩៩ ៦០២ | sorita@ocean-tech.biz |
| អ្នកស្រី ឡាយ កន្និកា | អគ្គលេខាធិការ | ០១៦ ៦៨៦ ៨២១ | laykanika៩១@gmail.com |
| លោកស្រី យូ បូរី | ហិរញ្ញិក | ០១៦ ៩៣៩ ៩៥៧ | bory.you@gmail.com |
| លោកស្រី គ្រីស្ទីន ហ្គោធៀរ | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកនវានុវត្តន៍ទីផ្សារ | ០១២ ៨១២ ៩៦៩ | ollivarydd@yahoo.com |
| អ្នកស្រី ជា សុខលាង | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកតស៊ូមតិ | ០៩៧ ៩៧៩ ៧៧៧៧ | leang_johnan@yahoo.com |
| លោកជំទាវ ម៉ម ដាត្តាលីណែត | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកអភិវឌ្ឍអាជីវកម្ម | ០៨១ ៧៨២ ២៨៨ | mamd@campure-company.com.kh |
| អ្នកស្រី ហង់ ជូនណារីតា | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកអភិវឌ្ឍអង្គភាព និងសមាជិកភាព | ០១៧ ២៩៨ ០៩៥ | narita.sareth@gmail.com |
| អ្នកស្រី ចាង សុខគីម | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកពង្រីកអង្គភាព | ០១៣ ៨៣៨ ៨២៤ | bayon_bakery@yahoo.com |
| អ្នកស្រី លីម វីរិយ៉ា | សមាជិកក្រុមប្រឹក្សា - ប្រធានផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង | ០១២ ៦៦៨ ៨៦៤ | limviriya@gmail.com |

សូមមើលឧបសម្ព័ន្ធ ១ សម្រាប់អង្គការលេខរបស់សមាគមសហាគ្រិនស្ត្រីកម្ពុជា និងតួនាទី ព្រមទាំងទំនួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សា។

## សេចក្តីផ្តើម

### ១. បុព្វកថា

ផែនការយុទ្ធសាស្ត្រត្រូវបានបង្កើតឡើង មានគោលបំណងឱ្យសមាជិកសមាគមសហគ្រិនស្ត្រីកម្ពុជាចូលរួមបានយ៉ាងបានសកម្ម ដើម្បីឱ្យពួកគាត់ចូលរួមពាក់ព័ន្ធ និងអាចទទួលបានជោគជ័យនៅក្នុងវិស័យធុរកិច្ច។

### ២. ដំណើរការ

ផែនការយុទ្ធសាស្ត្រ (ឆ្នាំ២០១៤ - ២០១៦) នេះ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់រួមគ្នាជាមួយនឹងក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា។

### ៣. គោលបំណង

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងរួមបញ្ចូលស្ត្រីកម្ពុជាដែលជាសហគ្រិនមានសក្តានុពល ថ្មី ទើបតែរះឡើង និងទើបតែមានការទទួលស្គាល់ ដើម្បីជំរុញឱ្យពួកគាត់ឱ្យក្លាយជាសហគ្រិនដែលមានប្រសិទ្ធភាព និងផលិតភាពខ្លាំងបំផុតតាមសក្តានុពលរបស់ពួកគាត់។

### ៤. ផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះផ្តល់ជូនជាទិដ្ឋភាពកាន់តែទូលំទូលាយអំពីគោលដៅរបស់យុទ្ធសាស្ត្ររយៈពេលបីឆ្នាំរបស់សមាគម ដោយពន្យល់អំពីមូលហេតុដែលសមាគមនេះត្រូវបានបង្កើតឡើង (ចក្ខុវិស័យសមាគម) ក្នុងនាមជាសមាគមមួយ ហើយសកម្មភាពដែលយើងបានប្តេជ្ញាចិត្តថានឹងសម្រេចឱ្យបាន (បេសកកម្មរបស់យើង)។ ផែនការយុទ្ធសាស្ត្រនេះក៏នឹងរៀបរាប់អំពីចំណុចយុទ្ធសាស្ត្រទាំងប្រាំមួយដែលយើងនឹងផ្តោតការខិតខំប្រឹងប្រែងរបស់យើងដើម្បីសម្រេចឱ្យបាននៅក្នុងរយៈពេល ៣ ឆ្នាំបន្ទាប់ផងដែរ។

### ៥. អាទិភាពយុទ្ធសាស្ត្រ

អាទិភាពយុទ្ធសាស្ត្រទាំងប្រាំមួយ គឺជាចំណុចសំខាន់ៗដែលយើងជឿជាក់ថាត្រូវយកចិត្តទុកដាក់ក្នុងនាមជាសមាគមនៅក្នុងរយៈពេល ១ ទៅ ៣ ឆ្នាំទៅមុខទៀត ដោយយើងមានគោលបំណងសម្រេចឱ្យបាននូវចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូលរបស់យើង។ អាទិភាពយុទ្ធសាស្ត្រនេះក៏មានរួមបញ្ចូលៈ

- "**គោលបំណងយុទ្ធសាស្ត្រ**"៖ ជាសេចក្តីពណ៌នាទូទៅអំពីសកម្មភាពដែលយើងចង់សម្រេចឱ្យបាននៅក្នុងរយៈពេល ១ ទៅ ៣ ឆ្នាំខាងមុខទៀត ហើយនិង
- "**លទ្ធផលយុទ្ធសាស្ត្រ**"៖ ជាសេចក្តីពណ៌នាអំពីលទ្ធផលសរុបដែលយើងនឹងទទួលបាននៅក្នុងចំណុចយុទ្ធសាស្ត្រទាំងនេះ  ក៏ដូចជាកំណត់បង្ហាញអំពីរបៀបដែលយើងនឹងវាស់វែងដំណើរការរបស់យើងផងដែរ។

## ៦. ការធ្វើផែនការយុទ្ធសាស្ត្រ

ផ្នែកនេះផ្តល់ជូននូវផែនទីបង្ហាញផ្លូវលម្អិតទៅលើដំណើរការរបស់ផែនការឱ្យបានកាន់តែច្បាស់លាស់ជាងមុន។

# ផ្នែកទី ១៖ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូលរបស់យើង

## ១.១ ចក្ខុវិស័យរបស់សមាគម

យើងចង់ឃើញសហគ្រិនស្ត្រីកម្ពុជា និងអាជីវកម្មរបស់ពួកគាត់ចាប់ផ្តើមដំណើរការ រីកចម្រើន និង ទទួលបានភាពជោគជ័យ នៅក្នុងវិស័យរបស់ពួកគាត់ និងបង្កើតឱ្យមានឥទ្ធិពលដ៏មានអត្ថន័យនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

## ១.២ បេសកកម្មរបស់សមាគម

បេសកកម្មរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា គឺលើកទឹកចិត្ត និងគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មដែលដឹកនាំដោយស្ត្រីនៅក្នុងប្រទេសកម្ពុជា។

## ១.៣ គោលបំណងរបស់សមាគម

សមាគមសហគ្រិនស្ត្រីកម្ពុជា មានគោលបំណងផ្តល់ជូនជាវេទិកាតំណាងមួយសម្រាប់ស្ត្រីដែលប្រកបអាជីវកម្ម ដើម្បីលើកឡើងអំពីបញ្ហាទៅកាន់រដ្ឋាភិបាល អាជីវកម្មសហគមន៍មហាជន និងប្រព័ន្ធផ្សព្វផ្សាយ ក្នុងគោលបំណងធ្វើឱ្យមជ្ឈដ្ឋានអាជីវកម្មមានភាពល្អប្រសើរជាងមុន ព្រមទាំងជួយសម្របសម្រួលការរីកចម្រើនរបស់សកម្មភាពអាជីវកម្ម ដែលរៀបចំឡើងដោយមានស្ត្រីចូលរួម។ យើងក៏មានគោលបំណងផ្តល់ជូននូវឱកាសក្នុងការបង្កើតបណ្តាញសម្រាប់សមាជិក ចែករំលែកព័ត៌មាន និងជួបជាមួយនឹងភាគីពាក់ព័ន្ធ ក៏ដូចជាចាត់ចែងការផ្តល់ពានរង្វាន់សម្រាប់វិស័យជាក់លាក់នានាផងដែរ។

## ១.៤ គុណតម្លៃស្នូលរបស់សមាគម

គុណតម្លៃស្នូលរបស់យើងគឺ៖

- ពង្រឹងភាពអង់អាច
- ភាពជាអ្នកដឹកនាំ
- តម្លាភាព
- គណនេយ្យភាព
- នវានុវត្តន៍

## ១. បរិបទរបស់សមាគម៖ បញ្ហា និងបញ្ហាប្រឈម - តម្រូវការឱ្យមានសហគ្រិនស្ត្រី[1]

ចំណែកទីផ្សារធំបំផុតនៃការងាររបស់ស្ត្រីគឺនៅក្នុងផ្នែកសេវាកម្ម និងការលក់ (៣០,៣ ភាគរយ) បន្ទាប់មកគឺមានការងារផ្នែកកសិកម្មជំនាញ (២៣,៦ ភាគរយ) ការងារបឋម (១៤ ភាគរយ) និង ប្រតិបត្តិការម៉ាស៊ីន (១៣,៩ ភាគរយ)។ ចំណែកទីផ្សារការងាររបស់ស្ត្រីមាន ៥៣,៦ ភាគរយនៅក្នុងវិស័យឧស្សាហកម្ម និង ១៤,២ ភាគរយនៅក្នុងវិស័យសេវាកម្ម។ ចំណែកទីផ្សារការងារស្ត្រីនៅក្នុង

[1] ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ (ILO) និង វិទ្យាស្ថានជាតិស្ថិតិ (NIS)

វិស័យសេវាកម្មមានត្រឹមតែ ១៤ ភាគរយប៉ុណ្ណោះ ដែលជាប្រធានប្រតិបត្តិ មន្ត្រីជាន់ខ្ពស់ និង សមាជិកសភា ហើយ ១៥,២ ភាគរយជាអ្នកគ្រប់គ្រងរដ្ឋបាល និងពាណិជ្ជកម្ម។

ការស្ទង់មតិបានរកឃើញថា ចំណែកទីផ្សារការងារស្ត្រីនៃការងារទាំងមូលដែលបានប៉ាន់ស្មានគឺ ៤៧,២ ភាគរយ ខណៈដែលចំណែកទីផ្សារការងារបុរសមាន ៥២,៨ ភាគរយ ដែលស្មើគ្នារវាងទីប្រជុំជន និងជនបទ។ បើគិតតាមប្រភេទការងារវិញ វិស័យដែលមានបុគ្គលិកស្ត្រីបំពេញការងារច្រើនជាងគេ គឺផ្នែកសេវាកម្ម និងផ្នែកលក់ (៦៥,៣ ភាគរយ) បន្ទាប់មកផ្នែកប្រតិបត្តិការរោងចក្រ និងម៉ាស៊ីន (៥៣,៣ ភាគរយ) បន្ទាប់មកទៀតគឺបុគ្គលិកជំនាញខាងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ (៤៧,៥ ភាគរយ)។

ចំណែកនៃបុគ្គលិកជាស្ត្រីនៅក្នុងការងារតាមប្រាក់ឈ្នួល និងប្រាក់ខែទាំងអស់ក្រៅពីវិស័យកសិកម្មគឺមាន ៤០,១ ភាគរយ ដែល ៤១,៧ ភាគរយនៃចំណែកនោះគឺនៅក្នុងតំបន់ជនបទ និង ៣៦,៤ ភាគរយគឺនៅក្នុងតំបន់ទីប្រជុំជន។ ទិដ្ឋភាពរីកចម្រើននេះ អាចនឹងត្រូវបានជំរុញមួយផ្នែកដោយការរីកចម្រើនជាបន្តបន្ទាប់នៃវិស័យកាត់ដេរនៅក្នុងប្រទេសកម្ពុជា។

សហគ្រិនស្ត្រី ដែលកំពុងដំណើរការអាជីវកម្មមីក្រូ និងអាជីវកម្មខ្នាតតូច នៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ ចូលរួមជាចំណែកដ៏ធំមួយនៅក្នុងសេដ្ឋកិច្ចជាតិ។ ក៏ប៉ុន្តែ ពួកគេមិនទាន់បានរាប់បញ្ចូលទៅក្នុងវិសាលភាពនៃគោលនយោបាយ និងកម្មវិធីសហគ្រាសខ្នាតតូច និងមធ្យមនៅឡើយនោះទេ។ សហគ្រិនស្ត្រីមានសិទ្ធិអំណាចតិចក្នុងការបង្កើតគំនិតផ្តួចផ្តើមថ្មីសម្រាប់សហគ្រាសខ្នាតតូច ដែលបណ្តាលឱ្យមានវិសមភាពក្នុងការបែងចែកធនធានរវាងបុរស និងស្ត្រី។

សហគ្រិនស្ត្រីអាចប្រឈមមុខនឹងឧបសគ្គពាក់ព័ន្ធនឹងយេនឌ័រជាច្រើនប្រភេទ ដែលអាចមានតាំងពីការចែករំលែកតួនាទីយេនឌ័រមិនស្មើគ្នា និងទំនាក់ទំនងនៅក្នុងគ្រួសារ ព្រមទាំងសង្គមទាំងមូល ការរើសអើងចំពោះការលក់ឬជួលអចលនទ្រព្យ/ការរើសអើងពាក់ព័ន្ធនឹងស្ថានភាពអាពាហ៍ពិពាហ៍ និងច្បាប់ស្នងមរតក និង/ឬការអនុវត្តវប្បធម៌ និងទំនៀមទម្លាប់ ព្រមទាំងការដាក់កំហិតទៅលើការផ្លាស់ទី/ការបញ្ចេញមតិ/ការតំណាង។ ពួកគាត់ក៏ខ្វះខាតការយល់ដឹង ចំណេះដឹង និងបទពិសោធន៍ក្នុងការប្រកបអាជីវកម្មផងដែរ។ បញ្ហាប្រឈមទាំងនេះរួមជាមួយនឹងការផាត់ចេញពីសង្គមមានន័យថា សហគ្រិនស្ត្រីមានឱកាសខ្ពស់ក្នុងការទទួលបានតួនាទីការងារទាបជាង បើប្រៀបធៀបជាមួយនឹងបុរស ឧទាហរណ៍នៅពេលដែលពួកគាត់ត្រូវការរកដើមទុនពីស្ថាប័នហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសលើអាជីវកម្មផ្សេងៗ ដើម្បីចាប់ផ្តើមបើក និងអភិវឌ្ឍអាជីវកម្មរបស់ពួកគាត់។ ដោយមិនមានទំនុកចិត្ត និងការគាំទ្ររឹងមាំសម្រាប់ការដឹកនាំអាជីវកម្មខ្នាតតូចរបស់ពួកគាត់នៅក្នុងប្រទេស ស្ត្រីរាប់ពាន់នាក់បានធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ហើយថែមទាំងបានជួបប្រទះនឹងការរំលោភបំពានសិទ្ធិស្ត្រីយ៉ាងធ្ងន់ធ្ងរដូចជាការរំលោភសេពសន្ថវៈ និងការជួញដូរមនុស្សជាដើម។

រហូតមកដល់ខែសីហា ឆ្នាំ ២០២០នេះ សមាគមសហគ្រិនស្ត្រីមានសមាជិកដែលបានចុះឈ្មោះចូលប្រហែល ៧០០ នាក់។

**សារតានៃវិស័យអាជីវកម្មរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា**




| | | | | | |
|---|---|---|---|---|---|
| សេវាកម្ម | ២៤% | បដិសណ្ឋារកិច្ច | ១២ % | សុខភាព/សម្ផស្ស | ៨% |
| ពាណិជ្ជកម្ម | ១៥% | សំណង់/អចលនទ្រព្យ | ១០% | ធនាគារ និងហិរញ្ញវត្ថុ | ៤% |
| រោងចក្រផលិត | ១៥% | ស្ថាប័ន/ផ្សេងៗ | ៩% | កសិកម្ម | ៣% |

# ផ្នែកទី ២ - អាទិភាព/តំបន់យុទ្ធសាស្ត្រ

យើងបានពង្រីកអាទិភាព/ផ្នែកជាយុទ្ធសាស្ត្រ សម្រាប់សមាគមសហគ្រិនស្ត្រីកម្ពុជារបស់យើង សម្រាប់រយៈពេល ៣ ឆ្នាំបន្ទាប់។ យើងមានការតស៊ូមតិដើម្បីឱ្យក្លាយទៅជាជាប្រភពនៃព័ត៌មានអំពីបញ្ហាប្រឈមរបស់សហគ្រិនស្ត្រីទាក់ទងនឹងជំនាញសហគ្រិន បញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងចីរភាព។

## អាទិភាពយុទ្ធសាស្ត្រទី១៖ ការតស៊ូមតិ/ការបញ្ចុះបញ្ចូល

### គោលបំណងយុទ្ធសាស្ត្រ

ដើម្បីបង្កើតសំឡេងតំណាងតែមួយជូនស្ថាប័នពាក់ព័ន្ធលើបញ្ហាអត្ថប្រយោជន៍រួម ក៏ដូចជាដើម្បីទាញចំណាប់អារម្មណ៍របស់រដ្ឋាភិបាល សហគមន៍អាជីវកម្មមហាជន និងប្រព័ន្ធផ្សព្វផ្សាយមកផ្តោតលើបញ្ហា។

### លទ្ធផលយុទ្ធសាស្ត្រ

យើងនឹងអាចឃើញមជ្ឈដ្ឋានអាជីវកម្មមានការរីកចម្រើន បញ្ហានឹងត្រូវបានលើកឡើងទៅកាន់រដ្ឋាភិបាល សហគមន៍អាជីវកម្ម និងប្រព័ន្ធផ្សព្វផ្សាយ មជ្ឈដ្ឋានអាជីវកម្មនឹងមានភាពល្អប្រសើរឡើង ហើយមានការសម្របសម្រួលលើការរីកចម្រើននៃអាជីវកម្ម និងសកម្មភាពដែលរៀបចំឡើងដោយមានការចូលរួមពីស្ត្រី។

## អាទិភាពយុទ្ធសាស្ត្រទី២៖ គណៈកម្មាធិការអភិវឌ្ឍអាជីវកម្ម

គណៈកម្មាធិការបង្កើតចំណូលនៃសមាគម

### អនុផ្នែក១៖ ការពង្រឹងសមត្ថភាព / ការបណ្តុះបណ្តាល

### គោលបំណងយុទ្ធសាស្ត្រ

ដើម្បីពង្រឹងភាពអង់អាចជូនដល់សហគ្រិនស្ត្រី ដើម្បីឱ្យពួកគាត់អាចដឹកនាំអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងទំនុកចិត្ត។

### លទ្ធផលយុទ្ធសាស្ត្រ

យើងនឹងឃើញស្ត្រីកាន់តែច្រើនដែលមានភាពម៉ឺងម៉ាត់ ហើយជាអ្នកដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសជាតិផងដែរ។

### អនុផ្នែក២៖ បណ្តាញអាជីវកម្ម

### គោលបំណងយុទ្ធសាស្ត្រ

ដើម្បីប្រមូលផ្តុំសហគ្រិនស្ត្រីកម្ពុជាទាំងអស់មកចែករំលែកបទពិសោធន៍ ចំណេះដឹង និងបង្ហាញអំពីអាជីវកម្ម ក៏ដូចជាផលិតផលរបស់ពួកគាត់។

### លទ្ធផលយុទ្ធសាស្ត្រ

យើងនឹងឃើញឱកាសកាន់តែច្រើននៅក្នុងការប្រកបអាជីវកម្ម ហើយទម្រង់នៃបណ្តាញ និងការប្រាស្រ័យទាក់ទងក៏មានការកើនឡើងផងដែរ។

### អនុផ្នែក- ៣៖ គណៈកម្មាធិការកម្មវិធី និងនវានុវត្តន៍

### គោលបំណងយុទ្ធសាស្ត្រ

ដើម្បីពាំនាំយកមកនូវសកម្មភាពដែលមានរបៀបរៀបរយជាងមុន និងព្រឹត្តិការណ៍ដែលបានគ្រោងទុកត្រឹមត្រូវ ហើយប្រមូលផ្តុំសហគ្រិនស្ត្រីកម្ពុជាទាំងអស់មកជុំគ្នា ហើយចូលរួមសំណេះសំណាលជាមួយនឹងអ្នកការទូត អង្គភាពរដ្ឋាភិបាល សមាជិកសមាគម ក្រុមប្រឹក្សានៃសមាគមសហគ្រិនស្ត្រីកម្ពុជា និងភ្ញៀវកិត្តិយសបុគ្គលសំខាន់ៗនានា។

**លទ្ធផលយុទ្ធសាស្ត្រ**

យើងនឹងឃើញមានកម្មវិធីជប់លៀង ឬព្រឹត្តិការណ៍ដែលបានគ្រោងទុក និងរៀបចំបានយ៉ាងល្អសម្រាប់សមាជិក និងភ្ញៀវកិត្តិយសទាំងអស់។

## អាទិភាពយុទ្ធសាស្ត្រទី ៣៖ ការអភិវឌ្ឍអង្គភាព

### អនុផ្នែក- ១៖ សមាជិកភាព និងការរៃអង្គាសថវិកា

**គោលបំណងយុទ្ធសាស្ត្រ**

ដើម្បីបង្កើនសមាជិកភាពរបស់យើង និងផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ល្អប្រសើរជូនដល់សមាជិករបស់យើង ព្រមទាំងដើម្បីឱ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ឱ្យពួកយើងអនុវត្តសកម្មភាពនានារបស់សមាគមបាន។

**លទ្ធផលយុទ្ធសាស្ត្រ៖** យើងនឹងកាន់តែមានចីរភាពជាងមុន ដោយមាននូវមូលនិធិគ្រប់គ្រាន់សម្រាប់សកម្មភាព និងប្រតិបត្តិការរបស់យើង។

យើងនឹងឃើញមានមូលដ្ឋានសមាជិកភាពរឹងមាំ និងច្រើនជាងមុន។

### អនុផ្នែក- ២៖ ការអភិវឌ្ឍអង្គភាព

**គោលបំណងយុទ្ធសាស្ត្រ**

ដើម្បីដំណើរការអង្គភាពដំណើរការទៅបានដោយឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ដោយមាននូវការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធដែលដំណើរការល្អ។

**លទ្ធផលយុទ្ធសាស្ត្រ៖**

យើងនឹងឃើញមានប្រព័ន្ធប្រាស្រ័យទាក់ទង និងប្រព័ន្ធហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពដំណើរការអង្គភាពកាន់តែមានប្រសិទ្ធផល និងសមាជិកក្រុមប្រឹក្សាមានការប្តេជ្ញាចិត្តកាន់តែរឹងមាំ។

## អាទិភាពយុទ្ធសាស្ត្រទី ៤៖ ការប្រាស្រ័យទាក់ទង និងទីផ្សារ (ទំនាក់ទំនងសាធារណៈ / ការចុះផ្សព្វផ្សាយ)

**គោលបំណងយុទ្ធសាស្ត្រ**

ដើម្បីធ្វើការប្រាស្រ័យទាក់ទងនៅក្នុងក្រុមប្រឹក្សា និងរវាងក្រុមប្រឹក្សា ព្រមទាំងសមាជិកក្រុមប្រឹក្សាឱ្យបានកាន់តែល្អប្រសើរជាងមុន។ ដើម្បីឱ្យមានទំនាក់ទំនងកាន់តែមានប្រសិទ្ធភាពជាងមុនពាក់ព័ន្ធនឹងការជូនដំណឹងជាសាធារណៈ និងកាន់តែងាយមើលឃើញ។

**លទ្ធផលយុទ្ធសាស្ត្រ**

យើងនឹងឃើញមានការប្រាស្រ័យទាក់ទងកាន់តែល្អប្រសើរ នៅក្នុងចំណោមសមាជិកក្រុមប្រឹក្សា និងរវាងក្រុមប្រឹក្សាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សា ដែលនឹងធ្វើឱ្យមានការយល់ដឹងច្បាស់ជាងមុន។ យើងនឹងឃើញថាមានការស្គាល់ និងការដឹងពីព័ត៌មានអំពីសមាគមសហគ្រិនស្ត្រីកម្ពុជាកាន់តែច្រើន ដែលនឹងបង្កើនការចូលរួមពីសាធារណជន។

# សមាគមសហគ្រិនស្ត្រីកម្ពុជា

**ចក្ខុវិស័យ៖** យើងចង់ឃើញសហគ្រិនស្ត្រីកម្ពុជា និងអាជីវកម្មរបស់ពួកគាត់ចាប់ផ្តើមដំណើរការ រីកចម្រើន និងទទួលបានភាពជោគជ័យ នៅក្នុងវិស័យរបស់ពួកគាត់ និងបង្កើតឱ្យមានឥទ្ធិពលដ៏មានអត្ថន័យនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

**បេសកកម្ម៖** យើងលើកទឹកចិត្ត និងគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មដែលដឹកនាំដោយស្ត្រីនៅក្នុងប្រទេសកម្ពុជា។

## ការរៀបចំផែនការយុទ្ធសាស្រ្ត និងរចនាសម្ព័ន្ធ

*"សមាគមសហគ្រិនស្ត្រីកម្ពុជា គឺជាតំណាងអ្នកដឹកនាំស្ត្រីនៅក្នុងវិស័យអាជីវកម្ម ដែលកំពុងមានឥទ្ធិពលថ្មីសន្លាង និងរីកចម្រើនឆាប់រហ័សទៅលើវិស័យការងារ និងសេដ្ឋកិច្ចនៅក្នុងប្រទេស"។*

ចក្ខុវិស័យ៖ គាំទ្រការរីកចម្រើននៃអាជីវកម្មដែលជាកម្មសិទ្ធិរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។

បេសកកម្ម៖ សហគ្រិនស្ត្រីជោគជ័យ បង្កើតឥទ្ធិពលប្រកបដោយអត្ថន័យនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

### ការតស៊ូមតិ និងការបញ្ចុះបញ្ចូល

ការលើកឡើងអំពីបញ្ហាជូនរដ្ឋាភិបាល សហគមន៍អាជីវកម្ម និងប្រព័ន្ធផ្សព្វផ្សាយ

**G-PSF**
១. បង្កើតវេទិកាសម្រាប់កំណត់រកបញ្ហា និងដំណោះស្រាយ
២. បង្កើនទំនាក់ទំនងរវាង ស.ស.ស.ក និងរដ្ឋាភិបាល អត្ថប្រយោជន៍អន្តរជាតិ និងភាគីពាក់ព័ន្ធ

**AWEN + GMEKONG**
១. បង្កើតវេទិកាតាមរយៈកំណត់សម្គាល់ទស្សនាទាន ដែលស្ត្រីភាគច្រើនអាចទទួលបានអត្ថប្រយោជន៍
២. បង្កើតក្រុមការងារដើម្បីដឹកនាំសកម្មភាពនៃកំណត់សម្គាល់ទស្សនាទាន

### ការអភិវឌ្ឍអាជីវកម្ម

ពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងការដឹកនាំអាជីវកម្មរបស់ពួកគាត់តាមរយៈការផ្តល់ជាធនធាន ឱកាស ការអប់រំ និងមធ្យោបាយចូលក្នុងទីផ្សារ។

**ការពង្រឹងសមត្ថភាព**
១. បណ្តុះបណ្តាលស្ត្រីអំពីភាពជាអ្នកដឹកនាំ
២. ផ្តល់ជូនសិក្ខាសាលាទាក់ទងនឹងអាជីវកម្ម
៣. ផ្តល់កម្មវិធីបង្ហាត់បង្រៀន
៤. សម្របសម្រួលទស្សនកិច្ចសិក្សា

**បណ្តាញ/ការប្រាស្រ័យទាក់ទងអាជីវកម្ម**
១. រៀបចំកម្មវិធីពិសេស
២. រៀបចំកម្មវិធីផ្គូរផ្គងអាជីវកម្ម និងកម្មវិធីបង្កើតបណ្តាញ
៣. រៀបចំសន្និសីទស្តីពីអាជីវកម្ម

**នវានុវត្តន៍ទីផ្សារ**
១. បង្កើតដំណោះស្រាយទីផ្សារ
២. រៀបចំពិព័រណ៍ពាណិជ្ជកម្ម និងការតាំងពិព័រណ៍
៣. បង្កើតហាងម៉ាកយីហោ ស.ស.ស.ក ចំណតយានយន្ត ឬវេទិកាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ការអភិវឌ្ឍអង្គភាព

ពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងការដឹកនាំអាជីវកម្មរបស់ពួកគាត់តាមរយៈការផ្តល់ជាធនធាន ឱកាស ការអប់រំ និងមធ្យោបាយចូលក្នុងទីផ្សារ។

**ការអភិវឌ្ឍសមាជិកភាព**
១. ធ្វើបច្ចុប្បន្នភាពលើប្រព័ន្ធផ្ទុកទិន្នន័យរបស់សមាជិក
២. បង្កើនការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពគ្រប់ប្រភេទឱ្យច្រើនជាងមុន
៣. កំណត់កម្មវិធីដែលនឹងផ្តល់ប្រយោជន៍ដល់ការយល់ដឹងអំពីទីផ្សារ
៤. ការចុះទស្សនកិច្ចផ្ទាល់តាមមូលដ្ឋានរបស់សមាជិក
៥. ធ្វើឱ្យអត្ថប្រយោជន៍ និងសេវាកម្មល្អប្រសើរជាងមុន
៦. កម្រិតសមាជិកភាព

**ការអភិវឌ្ឍអង្គភាព**
១. អភិបាលកិច្ចមានប្រសិទ្ធភាព
២. ធនធានហិរញ្ញវត្ថុ និងការចាត់ចែងថវិកាមានចីរភាព
៣. ប្រើប្រាស់បច្ចេកវិទ្យាដើម្បីផ្តល់ជំនួយក្នុងមុខងាររបស់សមាគមសហគ្រិនស្ត្រីកម្ពុជា
៤. វិនិយោគក្នុងការអភិវឌ្ឍបុគ្គលិក
៥. ភាពជាដៃគូ/កិច្ចសហប្រតិបត្តិការ
៦. ប្រកាប់ខ្ជាប់តាម D.E.T.A.I.L.S

### ទំនាក់ទំនងសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយ

បង្កើនការបញ្ចេញមុខមាត់របស់សមាគមសហគ្រិនស្ត្រីកម្ពុជា និងសមាជិករបស់ខ្លួនឱ្យបានច្រើនជាងមុនទៅសាធារណជនទូទៅ។

**ទីផ្សារ និងការប្រាស្រ័យទាក់ទង**
១. សាវតាសមាជិកភាពជាវីដេអូ
២. បញ្ជីរាយឈ្មោះសមាជិក
៣. កម្រិតលេចធ្លោនៃរូបសញ្ញារបស់សមាជិកនៅលើវេបសាយត៍
៤. ការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពរបស់សមាជិក

**ទំនាក់ទំនងសាធារណៈ/ប្រាស្រ័យទាក់ទងប្រព័ន្ធផ្សព្វផ្សាយ**
១ .សេចក្តីប្រកាសព័ត៌មានសម្រាប់កម្មវិធីពិសេស
២ .សន្និសីទកាសែតក្នុងកម្មវិធីពិសេស។

## រចនាសម្ព័ន្ធយុទ្ធសាស្ត្រ



# ផ្នែកទី ៣៖ ការរៀបចំផែនការយុទ្ធសាស្ត្រ

## អាទិភាពយុទ្ធសាស្ត្រទី១ ការតស៊ូមតិ/ការបញ្ចុះបញ្ចូល

**ពាក្យគន្លឹះ៖ កិច្ចការពារគោលនយោបាយ អត្ថប្រយោជន៍រយៈពេលវែង ការផ្សព្វផ្សាយ ការបញ្ចុះបញ្ចូល បញ្ហា និងបញ្ហាប្រឈម**

| | |
|---|---|
| **គោលបំណងយុទ្ធសាស្ត្រ**<br>អ្វីដែលយើងនឹងធ្វើ! | ដើម្បីបង្កើតសំឡេងតំណាងតែមួយជូនស្ថាប័នពាក់ព័ន្ធលើបញ្ហាអត្ថប្រយោជន៍រួម ក៏ដូចជាដើម្បីទាញចំណាប់អារម្មណ៍របស់រដ្ឋាភិបាល សហគមន៍អាជីវកម្មមហាជន និងប្រព័ន្ធផ្សព្វផ្សាយមកផ្តោតការយកចិត្តទុកដាក់លើបញ្ហា។ |
| **លទ្ធផលយុទ្ធសាស្ត្រ**<br>អ្វីដែលយើងនឹងឃើញ! | យើងនឹងអាចឃើញមជ្ឈដ្ឋានអាជីវកម្មមានការរីកចម្រើន បញ្ហានឹងត្រូវបានលើកឡើងទៅកាន់រដ្ឋាភិបាល សហគមន៍អាជីវកម្ម និងប្រព័ន្ធផ្សព្វផ្សាយ មជ្ឈដ្ឋានអាជីវកម្មនឹងមានភាពល្អប្រសើរឡើង ហើយនិងមានការសម្របសម្រួលលើការលូតលាស់រីកចម្រើននៃអាជីវកម្ម និងសកម្មភាពដែលរៀបចំឡើងដោយមានការចូលរួមពីស្ត្រី។ នេះគឺជាអត្ថប្រយោជន៍រយៈពេលវែងរបស់សហគ្រិនស្ត្រីគ្រប់រូប។ |

| **យុទ្ធសាស្ត្រ<br>(តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត)** | **វិធីសាស្ត្រ<br>(តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?)** | **ការវាស់វែង<br>(តើយើងនឹងដឹងបានដោយរបៀបណា?)** | **អ្នកណា?** | **គ្រោងពេលវេលា<br>(រហូតដល់ពេលណា?)** |
|---|---|---|---|---|
| **១. កិច្ចការរដ្ឋបាលតស៊ូមតិរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | បង្កើតអង្គការលេខតស៊ូមតិ | វត្តមានសាវតារនៃអង្គការលេខនៅក្នុងការិយាល័យរបស់ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា | គណៈកម្មាធិការតស៊ូមតិ | រួចរាល់ |
| | ពិនិត្យ និងធ្វើបច្ចុប្បន្នភាពធម្មនុញ្ញ (ឯកសាររស់) | នៅពេលដែលចាំបាច់ និងស្របពេលជាមួយនឹងកិច្ច | ទីប្រឹក្សារបស់ប្រធាន | ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ បានបំពេញរួចរាល់អស់បន្ត |

| | | | | |
|---|---|---|---|---|
| | | ប្រជុំថ្នាក់ដឹកនាំប្រចាំត្រីមាសរបស់អនុប្រធាន | | បន្ទាប់គ្នានៅរៀងរាល់ត្រីមាស។ (មករា មេសា កក្កដា និងតុលា) រហូតដល់ឆ្នាំ២០២២ |
| | រៀបចំដំណើរការលិខិតតែងតាំង | ចំនួនអ្នកដឹកនាំដែលបានបង្កើតឡើងនៅក្រោមការតស៊ូមតិ | ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមសហគ្រិនស្ត្រីកម្ពុជា | រួចរាល់។<br>សម្រាប់អ្នកដែលទើបតែត្រូវបានតែងតាំងថ្មី រៀងរាល់កិច្ចប្រជុំប្រចាំឆ្នាំរៀងរាល់បីឆ្នាំស្របពេលជាមួយនឹងអាណត្តិ |
| | រៀបចំដំណើរការបញ្ជាក់លិខិតតែងតាំង | ចំនួនក្រុមសីលធម៌ដែលបានចុះហត្ថលេខា និងបញ្ជាក់ | ការិយាល័យ<br>រដ្ឋបាលរបស់លេខាធិការដែលបានតែងតាំង | រៀងរាល់ការចេញលិខិតតែងតាំង មិនត្រូវលើសពី១ខែចាប់ពីកាលបរិច្ឆេទនៃការតែងតាំងឡើយ |
| | ដាក់ជូនបញ្ជីនៃប្រធាន និងអនុប្រធានបម្រើការងារនៅក្នុងសមាគមសហគ្រិនស្ត្រីកម្ពុជាជូនទៅកាន់ CCC សម្រាប់ជាឯកសារយោង និងការចូលរួម។ | ចំនួនក្រុមការងារដែលបានបង្កើតឡើង | រដ្ឋបាល<br>ប្រធាន<br>ប្រធានសមាគម | រួចរាល់។<br>រៀងរាល់ពេលបន្ទាប់ពីការតែងតាំង និងការពិនិត្យមើល |

| | | | | |
|---|---|---|---|---|
| | ពិនិត្យមើលឡើងវិញទៅលើផែនការយុទ្ធសាស្ត្រនៃការតស៊ូមតិ | ចំនួនសកម្មភាព និងគោលបំណង | ប្រធាន<br>ទីប្រឹក្សា<br>ប្រធានសមាគម | រៀងរាល់ត្រីមាសស្រប ពេលជាមួយនឹងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំត្រីមាស |
| | ការធ្វើបច្ចុប្បន្នភាពលើសកម្មភាពប្រចាំឆ្នាំ | រាយការណ៍នៅចុងឆ្នាំ | រដ្ឋបាល<br>ប្រធាន<br>ប្រធានសមាគម | តាមការចាំបាច់<br>មួយឆ្នាំម្តង |
| | ពិនិត្យឡើងវិញ / ធ្វើបច្ចុប្បន្នភាពលើរចនាសម្ព័ន្ធរបស់គណៈកម្មាធិការ | ចំនួនសមាជិកនៅក្នុងក្រុមតស៊ូមតិ | ប្រធាន<br>ទីប្រឹក្សា<br>ប្រធានសមាគម | តាមការចាំបាច់<br>មួយឆ្នាំម្តង |
| | ធ្វើការវាយតម្លៃសមិទ្ធផល / លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការលើចំនួនសកម្មភាពដែលបានអនុវត្ត | *ចំនួនបញ្ហាដែលបានស្នើទៅកាន់រដ្ឋាភិបាល *ចំនួនសំណើរបស់សមាគមសហគ្រិនស្ត្រីកម្ពុជាដែលបានផ្តល់ជូនដោយរដ្ឋាភិបាលសម្រាប់ការដាក់បញ្ចូលទៅក្នុងគោលនយោបាយ | *ប្រធាន<br>*អនុប្រធាន<br>*ប្រធានគណៈកម្មាធិការ<br>*អនុប្រធានគណៈកម្មាធិការ | ប្រចាំឆ្នាំ |
| | រៀបចំ និងបំពេញទម្រង់បែបបទ G-PSF អំពីបញ្ហាជាក់លាក់ និងអនុសាសន៍គោលនយោបាយ | ចំនួនបញ្ហាដែលបានឯកភាពដោយក្រុមប្រឹក្សា ហើយបញ្ជូនទៅកាន់ GPSF ថ្នាក់ជាតិ។ | ប្រធាន<br>អនុប្រធាន<br>*ប្រធានសមាគម | រៀងរាល់ឆ្នាំ ក្រុមការងារនីមួយៗត្រូវតែត្រៀមបំពេញឱ្យបានរួចរាល់អស់ដើម្បីដាក់ជូនរដ្ឋាភិបាលឱ្យ |

| | | | | |
|---|---|---|---|---|
| | | | | បានទាន់ពេលវេលា សម្រាប់ការកោះហៅប្រជុំ។ |
| | រាយការណ៍ និងផ្តល់ដំណឹងថ្មីៗទាក់ទងនឹងដំណើរការនៃសកម្មភាពជូនដល់ក្រុមប្រឹក្សា | ចំនួនរបាយការណ៍ / សំណើសុំដែលបានដាក់ជូនក្រុមប្រឹក្សាភិបាល | ប្រធាន | សមិទ្ធផលនៃសកម្មភាពនីមួយៗ |
| | រៀបចំ និងដាក់ជូនសំណើសុំក្រៅផ្លូវការ (white proposal) ដើម្បីបញ្ចុះបញ្ចូលក្រសួង | ចំនួនសំណើសុំក្រៅផ្លូវការដែលបានដឹងឮ និងទទួលយកដោយក្រសួងពាក់ព័ន្ធ | ក្រុមតស៊ូមតិទាំងមូល<br>ប្រធានសមាគម<br>ទីប្រឹក្សា | រៀងរាល់ឆ្នាំទីពីរ |
| **២. បង្កើតវេទិកាសម្រាប់ការកំណត់បញ្ហា និងដំណោះស្រាយ** | រៀបចំធ្វើវេទិកាបង្ហាញផ្លូវ (កិច្ចប្រជុំថ្នាក់ខេត្ត) ដើម្បីប្រមូលបញ្ហា និងបញ្ហាប្រឈមដែលសហគ្រិនស្ត្រីជួបប្រទះ | ចំនួននៃវេទិកាបង្ហាញផ្លូវដែលបានរៀបចំ<br>របាយការណ៍លើបញ្ហាដែលបានប្រមូល | ក្រុមកម្មវិធី<br>ប្រធាន<br>ក្រុមប្រឹក្សា | ពីរ ទៅបីខេត្តក្នុងមួយឆ្នាំ |
| | រៀបចំកិច្ចប្រជុំតុមូលនៅក្នុងទីក្រុងភ្នំពេញ | ចំនួនកិច្ចប្រជុំតុមូលដែលបានរៀបចំឡើង | ប្រធាន<br>អនុប្រធាន | ក្រុមការងារមួយក្រុមក្នុងមួយឆ្នាំ |
| | រៀបចំកិច្ចពិភាក្សាក្រុមគោលដៅ៖ ធ្វើការវាយតម្លៃ<br>- ការបង្កើតអ្នកតំណាងស្ត្រីសកម្មមួយរូបក្នុងមួយក្រុមការងារ | ចំនួននៃក្រុមគោលដៅដែលបានរៀបចំឡើង<br>របាយការណ៍សង្ខេបអំពីបញ្ហា | ជំនាញការ<br>ប្រធាន | តាមការចាំបាច់ និងអាចសរសេរលិខិតបង្ហាញគោលជំហររឹងមាំជាងមុន |

| | | | | |
|---|---|---|---|---|
| | បង្កើតការវាយតម្លៃ និង កម្រងសំណួរ | ចំនួនការវិភាគតម្រូវការ បណ្តុះបណ្តាល (TNA) ដែលបានបង្កើតឡើង | ដៃគូអភិវឌ្ឍ រដ្ឋបាល | រាល់ពេលបញ្ចប់នៃកម្មវិធី ណាមួយរបស់សមាជិកនៃ សមាគមសហគ្រិនស្ត្រី កម្ពុជា កិច្ចប្រជុំតុមូល ជាដើម។ |
| | រៀបចំ និងបង្កើតការស្ទង់ មតិរៀងរាល់ពេលចប់កម្មវិធី របស់សមាគមសហគ្រិនស្ត្រី កម្ពុជាពីគណៈកម្មាធិការ ផ្សេងៗគ្នា | *ចំនួនសមាជិកដែលបាន ចូលរួមក្នុងការឆ្លើយ កម្រងសំណួរ * របាយ ការណ៍* | | ឆ្នាំរដ្ឋបាល ២០២១ |
| | សហការជាមួយនឹងគណៈ កម្មាធិការបណ្តាញអាជីវកម្ម នៅក្នុង "សន្និសីទ" ការ ជជែក និង/ឬ កិច្ចពិភាក្សា គណៈកម្មាធិការ | ចំនួនអ្នកចូលរួម | ប្រធាន | រៀងរាល់ឆ្នាំ |
| | សហការជាមួយនឹងកិច្ចប្រជុំ តាមវិស័យនៃបណ្តាញ អាជីវកម្ម | ចំនួនអ្នកចូលរួម ចំនួនកិច្ចប្រជុំ | ប្រធាន | អាស្រ័យទៅលើកម្មវិធី របស់សមាគមអភិវឌ្ឍ អាជីវកម្ម |
| | សហការជាមួយនឹង សមាគម និងសភាដទៃ ទៀត | ចំនួនកម្មវិធីដែលបាន សហការ ចំនួនដៃគូ | ក្រុមតស៊ូមតិ រដ្ឋបាល | តាមការអញ្ជើញរបស់ដៃគូ |

| | | | | |
|---|---|---|---|---|
| | សហការជាមួយនឹង សមាគមស្ត្រីដទៃទៀតនៅ ប៉ែកខាងត្បូង និងខាងកើត នៃតំបន់អាស៊ី | ចំនួនកម្មវិធីដែលបាន សហការ ចំនួនដៃគូដែលយើងមាន នៅ SAWDF | ក្រុមតស៊ូមតិ រដ្ឋបាល | តាមការអញ្ជើញ ប្រចាំឆ្នាំយោងតាម CIPE |
| **៣. បង្កើនទំនាក់ទំនងរវាង សមាគមសហគ្រិនស្ត្រីកម្ពុជា រដ្ឋាភិបាល សម្ព័ន្ធអន្តរជាតិ និងភាគីពាក់ព័ន្ធតាមរយៈការ បង្កើនចំណេះដឹង និងការ យល់ដឹងរបស់អ្នកអំពី ព្រឹត្តិការណ៍បច្ចុប្បន្ន។** | ចូលរួមក្នុងកិច្ចប្រជុំដែល កោះហៅដោយក្រសួង សភា ដៃគូ ជាពិសេសនៅ ក្នុងដំណើរការពិគ្រោះ យោបល់ថ្នាក់ជាតិអំពី ប្រធានបទណាមួយដែល ត្រូវបានផ្ដល់អាទិភាពដោយ រដ្ឋាភិបាល។ | ចំនួនព្រឹត្តិការណ៍ដែល បានចូលរួម ចំនួនអ្នកចូលរួម | ក្រុមតស៊ូមតិ លេខាធិការដ្ឋាន ក្រុមប្រឹក្សា | តាមការអញ្ជើញ |
| | ទៅជួបជាមួយក្រសួងពាក់ ព័ន្ធជាការសួរសុខទុក្ខ | *ចំនួនដងនៃការទៅជួប *ចំនួនអ្នកដឹកនាំដែល បានជួបជាមួយក្រសួង | ការជ្រើសរើសពី ខាងក្រោមៈ ក្រុមតស៊ូមតិ លេខាធិការដ្ឋាន ក្រុមប្រឹក្សា | តាមគោលបំណង និងការ ចាំបាច់ ហើយរាល់ពេល ដែលមានកម្មវិធីពិសេស |
| | ដាក់សំណើក្រៅផ្លូវការជូន ដល់ក្រសួងពាក់ព័ន្ធ និងធ្វើ ការពិភាក្សា | ចំនួនសំណើក្រៅផ្លូវការ ដែលបានបង្កើត | ប្រធាន ក្រុមប្រឹក្សាភិបាល ប្រធានសមាគម | តាមសមិទ្ធផល / រៀងរាល់ បន្ទាប់ពី ២ ឆ្នាំម្ដង |
| | ចូលរួមនៅក្នុងតម្រង់ទិស នៃ GPSF ដើម្បីមាន | ចំនួនប្រធាន និងអនុ ប្រធាន | បេក្ខភាព អ្នកដឹកនាំសក្ដានុពល | ម្ដងសម្រាប់សមាជិកម្នាក់ៗ |

| | | | | |
|---|---|---|---|---|
| **៤. ការពង្រឹងសមត្ថភាព / ការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់មន្ត្រីតស៊ូមតិ** | លក្ខណៈគ្រប់គ្រាន់ និងយល់អំពីដំណើរការរបស់គណៈកម្មាធិការសម្រេចលើលក្ខណៈគ្រប់គ្រាន់របស់ G-PSF | ចំនួនអ្នកចូលរួមក្នុងការបណ្តុះបណ្តាល* | | ការតម្រង់ទិសគឺ ២ ដងក្នុងមួយឆ្នាំប៉ុន្តែគឺសម្រាប់តែអ្នកចូលរួមការបណ្តុះបណ្តាលថ្មីតែប៉ុណ្ណោះ។ |
| | ចូលរួមក្នុងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំតស៊ូមតិ | ចំនួននៃអ្នកចូលរួមបណ្តុះបណ្តាល<br>ចំនួននៃការបណ្តុះបណ្តាល | ប្រធាន និងអនុប្រធានតស៊ូមតិ | តាមកម្មវិធីដែលម្ចាស់ជំនួយឧបត្ថម្ភជូន |
| | ចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សា | ចំនួនព្រឹត្តិការណ៍<br>ចំនួនអ្នកចូលរួម | បេក្ខភាព<br>អ្នកដឹកនាំសក្តានុពល | តាមកម្មវិធីដែលម្ចាស់ជំនួយឧបត្ថម្ភជូន<br>តាមការអញ្ជើញពីដៃគូ |
| | ចូលរួមនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់របស់គណៈកម្មាធិការ | *ចំនួនព្រឹត្តិការណ៍<br>*ចំនួនអ្នកដឹកនាំដែលបានចូលរួម | គណៈកម្មាធិការតស៊ូមតិ | តាមកម្មវិធីដែលឧបត្ថម្ភដោយម្ចាស់ជំនួយមួយឆ្នាំម្តង |
| | ចូលរួមព្រឹត្តិការណ៍ដែលរៀបចំដោយគណៈកម្មាធិការដទៃទៀត | ចំនួនព្រឹត្តិការណ៍<br>ចំនួនបុគ្គលដែលបានចូលរួម | គណៈកម្មាធិការតស៊ូមតិ | តាមករណី<br>តាមស្ថានភាពទំនេររបស់គណៈកម្មាធិការតស៊ូមតិ |
| | ចូលរួមក្នុងការបណ្តុះបណ្តាល (ពិសេស និងអនុវត្តផ្ទាល់) អ្នកតំណាងតាមក្រុម | ចំនួនព្រឹត្តិការណ៍<br>ចំនួនបុគ្គលដែលបានចូលរួម | គណៈកម្មាធិការតស៊ូមតិ | តាមស្ថានភាពណាដែលទំនេរ |

| | | | | |
|---|---|---|---|---|
| | ការងារនីមួយៗនៅក្នុងការបង្ហាញអំពីបញ្ហាប្រឈមទៅកាន់រដ្ឋាភិបាល | | | |
| | ចូលរួមក្នុងសិក្ខាសាលាស្តីពីការកោះហៅជាសកលសម្រាប់សមភាពយេនឌ័រ និងការយល់ដឹងអំពីយេនឌ័រ | ចំនួនព្រឹត្តិការណ៍<br>ចំនួនបុគ្គលដែលបានចូលរួម | គណៈកម្មាធិការតស៊ូមតិ | តាមស្ថានភាពណាដែលទំនេរ |
| | ចូលរួមក្នុងការបង្កើត និងបញ្ចេញគំនិតដើម្បីរកឱ្យឃើញនូវបញ្ហាជាដុំកំភួនដើម្បីដាក់ជូន CCC។ | ចំនួននៃសំណើសង្ខេបដែលបានដាក់<br>ចំនួនកិច្ចប្រជុំដែលបានរៀបចំ | គណៈកម្មាធិការតស៊ូមតិ | កិច្ចប្រជុំប្រចាំត្រីមាស និងឬកិច្ចប្រជុំករណីពិសេសនៅពេលចាំបាច់ |

គោលការណ៍ណែនាំៈ

១. ត្រូវត្រៀមសំណើឱ្យបានរួចរាល់ជានិច្ច ហើយត្រូវយល់ដឹងអំពីបញ្ហាទូទៅនៃអ្វីដែលអ្នកកំពុងតែតំណាងឱ្យ។ បង្កើតផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមរបស់អ្នក ហើយរិះរកគំនិតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយពិនិត្យមើលគំនិតទាំងនោះ។

២. ត្រូវយល់ដឹងអំពីប្រកាសថ្មីៗ ក៏ដូចជាធានាឱ្យបានថា អ្នកយល់ដឹងអំពីច្បាប់ថ្មីៗ ហើយធ្វើការពិភាក្សានៅក្នុងវេទិកា។

៣. អានកាសែត និងតាមដានឱ្យបានជាប្រចាំចំពោះព្រឹត្តិការណ៍បច្ចុប្បន្ននៅក្នុងបណ្តាញសង្គមដែលទាក់ទងជាមួយនឹងស្ថានភាពអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ស្តាប់វិទ្យុនៅក្នុងរថយន្តរបស់អ្នកអំពីព័ត៌មានផ្សេងៗនៅក្នុង និងក្រៅប្រទេស។

៤. រក្សាទុកសំណៅថតចម្លងមួយច្បាប់នៃផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិនៃប្រទេសកម្ពុជា។

៥. អាន និងស្វែងយល់អំពីបញ្ហា និងអនុសាសន៍គោលនយោបាយរបស់សមាគមទាំងតាមសៀវភៅស និងតាមទម្រង់បែបបទ G-PSF

៦. និង។ល។

## អាទិភាពយុទ្ធសាស្ត្រទី ២៖ ការអភិវឌ្ឍអាជីវកម្ម
## អនុផ្នែកទី១ ការពង្រឹងសមត្ថភាព / ការបណ្តុះបណ្តាល

ពាក្យគន្លឹះ៖ ការពង្រឹងភាពអង់អាច ការពង្រីក ការអភិវឌ្ឍសេដ្ឋកិច្ច ការចូលរួម ការរៀនសូត្រ ការអភិវឌ្ឍជំនាញ

| | |
|---|---|
| គោលបំណងយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងធ្វើ! | ដើម្បីពង្រឹងភាពអង់អាចជូនដល់សហគ្រិនស្ត្រី ដើម្បីឱ្យពួកគាត់អាចដឹកនាំអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងទំនុកចិត្ត។ |
| លទ្ធផលយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងឃើញ! | យើងនឹងឃើញស្ត្រីកាន់តែច្រើនដែលមានភាពម៉ឺងម៉ាត់ ហើយជាអ្នកដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសជាតិផងដែរ។ |

| យុទ្ធសាស្ត្រ<br>(តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត) | វិធីសាស្ត្រ<br>(តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?) | ការវាស់វែង<br>(តើយើងនឹងដឹងបានដោយរបៀបណា?) | អ្នកណា? | គ្រោងពេលវេលា<br>(រហូតដល់ពេលណា?) |
|---|---|---|---|---|
| **១. មុនពេលវាយតម្លៃ និងក្រោយពេលវាយតម្លៃ** | ការស្ទង់មតិ និងកម្រងសំណួរ ព្រមទាំងលទ្ធផលពីវេទិកាតុមូល/វេទិកាបង្ហាញផ្លូវ អំពីការប្រឹងប្រែងពុះពារលើការអភិវឌ្ឍសមត្ថភាពរបស់សហគ្រិនស្ត្រី | ការរាយការណ៍ទិន្នន័យលើតម្រូវការរបស់សមាជិកសម្រាប់ការពង្រឹងសមត្ថភាព។ | ក្រុមប្រឹក្សានៃសមាគមសហគ្រិនស្ត្រី<br>អ្នកពិគ្រោះយោបល់<br>គណៈកម្មាធិការអនុវត្ត<br>បុគ្គលិក | ត្រីមាសទី ៤ |
| **២. ការអភិវឌ្ឍកម្មវិធី / គ្លីនិកអាជីវកម្ម** | ពិនិត្យមើលការស្ទង់មតិ កំណត់ប្រធានបទដែលត្រូវការ | ចំនួននៃម៉ូឌុលដែលបានបង្កើត | ជំនាញការ<br>បុគ្គលិក | ត្រីមាសទី ៥ |
| **៣. ការអនុវត្តសិក្ខាសាលា / ការបណ្តុះបណ្តាលជំនាញអាជីវកម្ម** | រៀបចំសិក្ខាសាលាស្តីពីការអភិវឌ្ឍជំនាញអាជីវកម្ម<br>បច្ចេកវិទ្យាថ្មី<br>បណ្តាញសង្គម (វេបសាយត៍ facebook, twitter ប្លុក (Blogs) សារ SMS) | ចំនួនសិក្ខាសាលា<br>ចំនួនអ្នកចូលរួម | បុគ្គលិក<br>ក្រុមពង្រឹងសមត្ថភាព | ត្រីមាសទី ៦ |
| **៤. តាមដាន និងវាយតម្លៃ (M&E)** | កម្រងសំណួរ | ចំនួនសន្លឹកដែលបានឆ្លើយរួចរាល់ | បុគ្គលិក<br>អ្នកចូលរួម | នៅពេលបញ្ចប់សិក្ខាសិលានីមួយៗ |

| | | | | |
|---|---|---|---|---|
| **៥. ការបង្រៀនណែនាំ និង ការបង្ហាត់** | កម្មវិធីបង្រៀនណែនាំបងប្អូនស្រី<br>- ការចែករំលែកព័ត៌មាន<br>- ការបង្រៀនណែនាំ / ការប្រឹក្សាពិសេស<br>- ការបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាល | ចំណេះដឹង និងទំនុកចិត្តរបស់សហគ្រិនមានការកើនឡើង | បុគ្គលិក<br>គណៈកម្មាធិការ | ឆ្នាំទី ២ និងឆ្នាំទី ៣ |

## អនុផ្នែកទី២៖ ការបង្កើតបណ្តាញអាជីវកម្ម

**ពាក្យគន្លឹះ៖ ប្រសិទ្ធផល ប្រសិទ្ធភាព មានរបៀប ភាពច្បាស់លាស់**

| | |
|---|---|
| **គោលបំណងយុទ្ធសាស្ត្រ**<br>អ្វីដែលយើងនឹងធ្វើ! | **ដើម្បីប្រមូលផ្តុំសហគ្រិនស្ត្រីកម្ពុជាទាំងអស់មកចែករំលែកបទពិសោធន៍ ចំណេះដឹង និងបង្ហាញអំពីអាជីវកម្ម ក៏ដូចជាផលិតផលរបស់ពួកគាត់។** |
| **លទ្ធផលយុទ្ធសាស្ត្រ**<br>អ្វីដែលយើងនឹងឃើញ! | **យើងនឹងឃើញឱកាសកាន់តែច្រើននៅក្នុងការប្រកបអាជីវកម្ម ហើយទម្រង់នៃបណ្តាញ និងការប្រាស្រ័យទាក់ទងក៏មានការកើនឡើងផងដែរ។** |

| **យុទ្ធសាស្ត្រ**<br>**(តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត)** | **វិធីសាស្ត្រ**<br>**(តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?)** | **ការវាស់វែង**<br>**(តើយើងនឹងដឹងបានដោយរបៀបណា?)** | **អ្នកណា?** | **គ្រោងពេលវេលា**<br>**(រហូតដល់ពេលណា?)** |
|---|---|---|---|---|
| **១. កម្មវិធីជាប្រចាំ** | e-BN - ការបង្កើតបណ្តាញអាជីវកម្មតាមរយៈកម្មវិធី Zoom អាស្រ័យលើលទ្ធផលនៃការស្ទង់មតិ | ចំនួនអ្នកចូលរួម<br>ចំនួនកិច្ចប្រជុំ | គណៈកម្មាធិការបង្កើតបណ្តាញអាជីវកម្ម | រៀងរាល់មួយខែម្តង |
| | ការបង្កើតបណ្តាញអាជីវកម្មតាមរយៈការជួបគ្នាផ្ទាល់ដោយអាស្រ័យលើការវាយតម្លៃតម្រូវការរបស់សមាជិក | ចំនួនអ្នកចូលរួម<br>ចំនួនកិច្ចប្រជុំ | គណៈកម្មាធិការបង្កើតបណ្តាញអាជីវកម្ម | រៀងរាល់មួយត្រីមាសម្តង |

| | | | | |
|---|---|---|---|---|
| | ឌីជីថល - ឧស្សាហកម្ម ៤.០ សភាពធម្មតាតាមបែបគន្លងថ្មី | ចំនួនអ្នកចូលរួម<br>ចំនួនកិច្ចប្រជុំ | គណៈកម្មាធិការបង្កើតបណ្ដាញអាជីវកម្ម | ពិសេស |
| **២. កម្មវិធីពិសេស** | ការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់<br>ការសម្ពោធចាប់ផ្ដើមគម្រោង និងការប្រកាសជូនដំណឹងអំពីពិធីផ្សេងៗទៀត | ចំនួនអ្នកចូលរួម<br>ចំនួនកិច្ចប្រជុំ | គណៈកម្មាធិការបង្កើតបណ្ដាញអាជីវកម្ម | ពិសេស |
| **៣. កម្មវិធីធំៗពិសេស** | មហាសន្និបាតប្រចាំឆ្នាំ<br>កម្មវិធី GALA របស់សមាគមសហគ្រិនស្ត្រីកម្ពុជា<br>ទិវាសហគ្រិនស្ត្រី (CWED) | ចំនួនអ្នកចូលរួម<br>ចំនួនកិច្ចប្រជុំ<br>របាយការណ៍ | គណៈកម្មាធិការបង្កើតបណ្ដាញអាជីវកម្ម | រៀងរាល់ខែមីនា<br>រៀងរាល់ខែមីនា<br>រៀងរាល់ខែសីហា |
| **៤. បណ្ដាញអាជីវកម្មក្នុងតំបន់** | សហគ្រិនស្ត្រីផ្ដើម | ចំនួនអ្នកទទួលពានរង្វាន់ | បណ្ដាញសហគ្រិនស្ត្រីកម្ពុជា (CAMWEN) | រៀងរាល់ខែមេសា<br>អាចមានការផ្លាស់ប្ដូរ |

## អនុផ្នែកទី៣៖ គណៈកម្មាធិការកម្មវិធី និងនវានុវត្តន៍ទីផ្សារ

**ពាក្យគន្លឹះ៖ រៀបចំ ធ្វើផែនការ នវានុវត្តន៍ សម្របសម្រួល**

| | |
|---|---|
| គោលបំណងយុទ្ធសាស្ត្រ | ដើម្បីពាំនាំយកមកនូវសកម្មភាពដែលមានរបៀបរៀបរយជាងមុន និងព្រឹត្តិការណ៍ដែលបានគ្រោងទុកត្រឹមត្រូវ ហើយប្រមូលផ្តុំសហគ្រិនស្ត្រីកម្ពុជាទាំងអស់មកផ្តុំគ្នា ហើយចូលរួមសំណេះសំណាលជាមួយនឹងអ្នកការទូត អង្គភាពរដ្ឋាភិបាល សមាជិកសមាគម ក្រុមប្រឹក្សានៃសមាគមសហគ្រិនស្ត្រីកម្ពុជា និងភ្ញៀវកិត្តយសបុគ្គលសំខាន់ៗនានា។ |
| លទ្ធផលយុទ្ធសាស្ត្រ | វត្តមាននៃផលិតផលកម្ពុជានៅក្នុងអាស៊ាន អឺរ៉ុប និង/ឬនៅក្នុងប្រទេស។ |

| យុទ្ធសាស្ត្រ<br>(តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត) | វិធីសាស្ត្រ<br>(តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?) | ការវាស់វែង<br>(តើយើងនឹងដឹងបានដោយរបៀបណា?) | អ្នកណា? | គ្រោងពេលវេលា<br>(រហូតដល់ពេលណា?) |
|---|---|---|---|---|
| **១. កម្មវិធីពាណិជ្ជកម្មក្នុងប្រទេស** | កោះពេជ្រ សហការជាមួយនឹងសមាគមលក់គ្រឿងអលង្ការ | ការលក់កើនឡើង និងមានការចូលរួមពីអ្នកចូលរួម | គណៈកម្មាធិការនវានុវត្តន៍ទីផ្សារ | ចន្លោះខែមេសា និងខែមិថុនា |
| **២. កម្មវិធីពាណិជ្ជកម្មក្នុងតំបន់** | តាមរយៈតំណរភ្ជាប់ QWEN | ការមានវត្តមាន | គណៈកម្មាធិការនវានុវត្តន៍ទីផ្សារ | អាស្រ័យលើបណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN) |
| **៣. កម្មវិធីពាណិជ្ជកម្មអន្តរជាតិ** | តាមរយៈ CBI - ទីផ្សារអឺរ៉ុបសម្រាប់ផលិតផលក្នុងផ្ទះ | ការលក់កើនឡើង | គណៈកម្មាធិការនវានុវត្តន៍ទីផ្សារ | អាស្រ័យលើ CBI |

## អាទិភាពយុទ្ធសាស្ត្រទី ៣៖ ការអភិវឌ្ឍអង្គភាព
### អនុផ្នែកទី១៖ សមាជិកភាព

ពាក្យគន្លឹះ៖ បង្កើន ចីរភាព លក្ខណៈសម្បត្តិគ្រប់គ្រាន់ (សមាជិក) អត្ថប្រយោជន៍

| | |
|---|---|
| គោលបំណងយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងធ្វើ! | ដើម្បីបង្កើនសមាជិកភាពរបស់យើង និងផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ល្អប្រសើរជូនដល់សមាជិករបស់យើង ព្រមទាំងដើម្បីឱ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ឱ្យពួកយើងអនុវត្តសកម្មភាពនានារបស់សមាគមបាន។ |
| លទ្ធផលយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងឃើញ! | យើងនឹងឃើញមានមូលដ្ឋានសមាជិកភាពរឹងមាំ និងច្រើនជាងមុន។ យើងនឹងកាន់តែមានចីរភាពជាងមុន ដោយមាននូវមូលនិធិគ្រប់គ្រាន់សម្រាប់សកម្មភាព និងប្រតិបត្តិការរបស់យើង។ |

| យុទ្ធសាស្ត្រ<br>(តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត) | វិធីសាស្ត្រ<br>(តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?) | ការវាស់វែង<br>(តើយើងនឹងដឹងបានដោយរបៀបណា?) | អ្នកណា? | គ្រោងពេលវេលា<br>(រហូតដល់ពេលណា?) |
|---|---|---|---|---|
| **១. សមាជិកភាពកើនឡើង** | - ការប្រាស្រ័យទាក់ទងគ្នា/ការធ្វើទីផ្សារ (ដោយប្រើមធ្យោបាយដែលមានស្រាប់ និងថ្មីៗ (ឧ. បណ្តាញសង្គម (Facebook; Twitter ជាដើម)) ពាក្យនិយាយតៗគ្នា សមាជិកសមាគមអញ្ជើញសមាជិកសក្តានុពលថ្មីៗដោយផ្ទាល់ បណ្តាញផ្សព្វផ្សាយ (វិទ្យុ [NRG] ជាដើម)<br>- ការផ្សព្វផ្សាយ (កូនសៀវភៅ/ខិតប័ណ្ណ ទស្សនាវដ្តី)<br>- ត្រូវការធ្វើបច្ចុប្បន្នភាពលើទម្រង់បែបបទដាក់ពាក្យ - ធ្វើឱ្យមានភាពទាក់ទាញ និងច្បាស់លាស់ជាងមុន | - ចំនួននៃកិច្ចប្រជុំ / ការរាយការណ៍ជាមួយភាគីពាក់ព័ន្ធផ្សេងៗ<br>- ចំនួនកូនសៀវភៅខិតប័ណ្ណដែលបានចែក<br>- បានបញ្ចប់ និងចែកជូនសមាជិក<br>- ចំនួននៃបញ្ជីរាយឈ្មោះដែលបានចែកជូន<br>- ចំនួននៃកិច្ចប្រជុំ និងរបាយការណ៍ | គណៈកម្មាធិការសមាជិកភាព | កំពុងបន្ត |

| | | | | |
|---|---|---|---|---|
| | - ប្រើប្រាស់បញ្ជីរាយឈ្មោះសមាជិកភាពរបស់យើង ដើម្បីទាក់ទាញអ្នកដទៃ<br>- កន្លែងផ្សព្វផ្សាយនៅតាមកិច្ចប្រជុំភាគីពាក់ព័ន្ធ / ម្ចាស់ឧបត្ថម្ភ ("ជម្រុញ" / ផ្សព្វផ្សាយ សមាជិកភាព និងព្រឹត្តិការណ៍បន្ទាប់ទៀត)<br>- កម្មវិធី App ចុះឈ្មោះ | | | |
| **២. ការរក្សាសមាជិក** | ការចុះទៅជួបសមាជិក កិច្ចប្រជុំប្រចាំត្រីមាស ដំណើរកំសាន្តជាមួយសមាជិក | ចំនួននៃការបន្តសុពលភាព | គណៈកម្មាធិការសមាជិកភាព | សមាជិក ២ នាក់ក្នុងមួយខែ រៀងរាល់ត្រីមាស មួយដង ទៅពីរដងក្នុងមួយឆ្នាំ |
| **៣. សកម្មភាពផ្សេងៗ** | ការរៃអង្គាសថវិកា ស្វែងរកជំនួយពីអ្នកឧបត្ថម្ភ និងដៃគូ ឱកាសក្នុងការហ្វឹកហាត់ការសម្រាប់សិស្សានុសិស្ស | ចំនួននៃកិច្ចសហការ | គណៈកម្មាធិការសមាជិកភាព | ពិសេស |

## អនុផ្នែកទី ២៖ ការពង្រីកអង្គភាព

**ពាក្យគន្លឹះ៖ បង្កើន ចីរភាព អត្ថប្រយោជន៍ ប្រសិទ្ធផល ប្រសិទ្ធភាព មានរបៀបរៀបរយ ភាពច្បាស់លាស់**

| | |
|---|---|
| គោលបំណងយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងធ្វើ! | ដើម្បីដំណើរការអង្គភាពដំណើរការទៅបានដោយឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ដោយមាននូវការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធដែលដំណើរការល្អ។ |
| លទ្ធផលយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងឃើញ! | យើងនឹងឃើញមានប្រព័ន្ធប្រាស្រ័យទាក់ទង និងប្រព័ន្ធហិរញ្ញវត្ថុដែលមានប្រសិទ្ធភាព ដំណើរការអង្គភាពកាន់តែមានប្រសិទ្ធផល និងសមាជិកក្រុមប្រឹក្សាមានការប្តេជ្ញាចិត្តកាន់តែរឹងមាំ។ |

| យុទ្ធសាស្ត្រ (តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត) | វិធីសាស្ត្រ (តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?) | ការវាស់វែង (តើយើងនឹងដឹងបានដោយរបៀបណា?) | អ្នកណា? | គ្រោងពេលវេលា (រហូតដល់ពេលណា?) |
|---|---|---|---|---|
| **ការចូលរួមក្នុងអនុស្សរណៈនៃការយោគយល់ ជាមួយនឹងដៃគូផ្សេងៗ** | ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាមួយនឹងដៃគូផ្សេងៗ (ស្ថានទូត សភា ក្រសួង ជាដើម) | ចំនួននៃដៃគូ | បុគ្គលិក គណៈកម្មាធិការសមាជិកភាព | កំពុងបន្ត |
| **ផែនការពង្រីកដំណាក់កាលទី១** | សាខាតាមខេត្ត - ខេត្តសៀមរាប បាត់ដំបង កំពង់ធំ មណ្ឌលគីរី ភ្នំពេញ | ចំនួនសាខា និងសមាជិក | បុគ្គលិក គណៈកម្មាធិការសមាជិកភាព | ឆ្នាំ២០១៩ និងឆ្នាំ២០២០ និងឆ្នាំ២០២១ |
| **ផែនការពង្រីកដំណាក់កាលទី២** | ៥ ខេត្ត | ចំនួនសាខា និងសមាជិក | បុគ្គលិក គណៈកម្មាធិការសមាជិកភាព | ឆ្នាំ២០២២ និងឆ្នាំ២០២៣ |
| **ផែនការពង្រីកដំណាក់កាលទី៣** | ៥ ខេត្ត | ចំនួនសាខា និងសមាជិក | បុគ្គលិក គណៈកម្មាធិការសមាជិកភាព | ឆ្នាំ២០២៤ និងឆ្នាំ២០២៥ |

## អាទិភាពយុទ្ធសាស្ត្រទី ៩៖ ការប្រាស្រ័យទាក់ទង និងទីផ្សារ / ទំនាក់ទំនងសាធារណៈ / ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ

**ពាក្យគន្លឹះ៖** ការសន្ទនា ភាពច្បាស់លាស់ ការយល់ដឹងរបស់សមាជិក ការចែករំលែកព័ត៌មាន មានរបៀបរៀបរយ

| | |
|---|---|
| គោលបំណងយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងធ្វើ! | ដើម្បីធ្វើការប្រាស្រ័យទាក់ទងនៅក្នុងក្រុមប្រឹក្សា និងរវាងក្រុមប្រឹក្សា ព្រមទាំងសមាជិកក្រុមប្រឹក្សាឱ្យបានកាន់តែល្អប្រសើរជាងមុន។ ដើម្បីឱ្យមានទំនាក់ទំនងកាន់តែមានប្រសិទ្ធភាពជាងមុនពាក់ព័ន្ធនឹងការជូនដំណឹងជាសាធារណៈ និងកាន់តែងាយមើលឃើញ។ |
| លទ្ធផលយុទ្ធសាស្ត្រ<br>អ្វីដែលយើងនឹងឃើញ! | យើងនឹងឃើញមានការប្រាស្រ័យទាក់ទងកាន់តែល្អប្រសើរ នៅក្នុងចំណោមសមាជិកក្រុមប្រឹក្សា និងរវាងក្រុមប្រឹក្សាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សា ដែលនឹងធ្វើឱ្យមានការយល់ដឹងច្បាស់ជាងមុន។ យើងនឹងឃើញថាមានការស្គាល់ និងការដឹងពីព័ត៌មានអំពីសមាគមសហគ្រិនស្ត្រីកម្ពុជាកាន់តែច្រើន ដែលនឹងបង្កើនការចូលរួមពីសាធារណជន។ |

| យុទ្ធសាស្ត្រ (តើយើងចង់ធ្វើ "អ្វី"? - ព័ត៌មានលម្អិត) | វិធីសាស្ត្រ (តើយើងនឹងអនុវត្តសកម្មភាពនោះដោយ "របៀបណា"?) | ការវាស់វែង (តើយើងនឹងដឹងបានដោយរបៀបណា?) | អ្នកណា? | គ្រោងពេលវេលា (រហូតដល់ពេលណា?) |
|---|---|---|---|---|
| | | | | |
| **១. វីដេអូទីផ្សាររបស់សមាជិក៖ ដើម្បីផ្តល់ជូនតម្លៃល្អដល់សមាជិក ដើម្បីឱ្យពួកគាត់មានវីដេអូទីផ្សាររៀងៗខ្លួនក្នុងការផ្សព្វផ្សាយ ដែលពួកគាត់អាចប្រើប្រាស់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។** | រៀបចំអនុស្សរណៈនៃការយោគយល់ និងសម្រង់តម្លៃដៃគូជាមួយនឹងសមាជិកណាម្នាក់នៃសមាគមសហគ្រិនស្ត្រីកម្ពុជា អំពីអាជីវកម្មធ្វើវីដេអូ ហើយផ្តល់ជូនតម្លៃល្អសម្រាប់សមាជិក | ចំនួនសមាជិកដែលប្រើប្រាស់កម្មវិធីនេះ | ប្រធានគណៈកម្មាធិការ និងមន្ត្រីការិយាល័យលទ្ធកម្ម | ត្រីមាសទី១ ឆ្នាំ២០២០ (បន្តរៀងរាល់ត្រីមាស) |
| | ពង្រឹងសមត្ថភាពសមាជិកអំពីរបៀបធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលសាមញ្ញដោយខ្លួនឯង | ចំនួនកម្មវិធីដែលបានរៀបចំ<br>ចំនួនសមាជិកដែលបានចូលរួម | លេខាធិការដ្ឋាន<br>សំណើរបស់ម្ចាស់ជំនួយ | ត្រីមាសទី១ ឆ្នាំ២០២០ (បន្តរៀងរាល់ត្រីមាស) |
| **២. កម្មវិធី App របស់សមាគមសហគ្រិនស្ត្រីកម្ពុជា (តាមដាន និងពិនិត្យមើលដើម្បីធ្វើការកែលម្អ)** | ពិនិត្យមើលឡើងវិញ និងណែនាំអំពីការកែលម្អ<br>• កម្មវិធី App បញ្ជីរាយឈ្មោះ<br>• កម្មវិធី App ចុះឈ្មោះសមាជិក | ចំនួនសេចក្តីណែនាំដែលប្រមូលបាន<br>ចំនួនសមាជិកដែលប្រើកម្មវិធី App | អ្នកដឹកនាំគណៈកម្មាធិការយុទ្ធសាស្ត្រ | ត្រីមាសទី១ ឆ្នាំ២០២០ (បន្តរៀងរាល់ត្រីមាស) |

| | | | | |
|---|---|---|---|---|
| | សិក្ខាសាលាស្តីពីកម្មវិធី App និងការផ្សព្វផ្សាយអំពីកម្មវិធី App | ចំនួនអ្នកចូលរួម ចំនួននៃកម្មវិធី / ព្រឹត្តិការណ៍ដែលបានរៀបចំ | លេខាធិការដ្ឋាន / សំណើរបស់ម្ចាស់ជំនួយ | ដើម្បីធ្វើជាដៃគូ និងសហការជាមួយនឹងគណៈកម្មាធិការសមាជិកភាពនៃសមាគមសហគ្រិនស្ត្រីកម្ពុជានៅក្នុងកិច្ចប្រជុំសមាជិកប្រចាំត្រីមាសជាប្រចាំ និងស្នើសុំចន្លោះពេលវេលាសម្រាប់ការធ្វើបច្ចុប្បន្នភាពអំពីគណៈកម្មាធិការប្រព័ន្ធផ្សព្វផ្សាយ។ |
| **៣. វេបសាយត៍ / Facebook / Telegram / Twitter របស់សមាគមសហគ្រិនស្ត្រីកម្ពុជា (តាមដាន និងពិនិត្យដើម្បីកែលម្អ)** | ធ្វើបច្ចុប្បន្នភាពលើគណនីបណ្តាញសង្គម | ចំនួនអ្នកចូលមើលបណ្តាញសង្គម | អ្នកដឹកនាំគណៈកម្មាធិការយុទ្ធសាស្ត្រ | ឆាប់ៗតាមដែលអាចធ្វើទៅបាន |
| | បង្កើតឆានែល Youtube ផ្ទាល់ខ្លួនរបស់សមាគមសហគ្រិនកម្ពុជា | ចំនួនអ្នកចូលមើលបណ្តាញសង្គម | អ្នកដឹកនាំគណៈកម្មាធិការយុទ្ធសាស្ត្រ | ឆាប់ៗតាមដែលអាចធ្វើទៅបាន |
| | រៀបចំសិក្ខាសាលាស្តីពីរបៀបធ្វើឱ្យរូបភាពមានលក្ខណៈវិជ្ជាជីវៈនៅក្នុងបណ្តាញសង្គម | ចំនួនអ្នកចូលមើលបណ្តាញសង្គម | អ្នកដឹកនាំគណៈកម្មាធិការយុទ្ធសាស្ត្រ + លេខាធិការដ្ឋាន | ឆាប់ៗតាមដែលអាចធ្វើទៅបាន |
| | Boost គណនីបណ្តាញសង្គមរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា | ចំនួនអ្នកចូលមើលបណ្តាញសង្គម | អ្នកដឹកនាំគណៈកម្មាធិការយុទ្ធសាស្ត្រ + ម្ចាស់ឧបត្ថម្ភ | ឆាប់ៗតាមដែលអាចធ្វើទៅបាន |

| | | | | |
|---|---|---|---|---|
| **៤. ក្រុមសន្ទនារបស់សមាគមសហគ្រិនស្ត្រីកម្ពុជា (តាមដាន និងពិនិត្យដើម្បីកែលម្អ)** | បង្កើតសមាជិកសកម្មនៅឆ្នាំ ២០២០ សម្រាប់តែព្រឹត្តិការណ៍ប៉ុណ្ណោះ ហើយមិនមានសមាជិកណាម្នាក់អាចសរសេរ comment និងបន្ថែមបុគ្គលណាម្នាក់ចូលក្នុងក្រុមឡើយ។ | ចំនួនសមាជិកថ្មី និងសមាជិកដែលបានបន្តសុពលភាព ចំនួនសមាជិកដែលគាំទ្រសមាគមសហគ្រិនកម្ពុជាសកម្ម | ការិយាល័យលេខាធិការដ្ឋាននៃសមាគមសហគ្រិនស្ត្រីកម្ពុជា | ខែមករា ឆ្នាំ២០២០ - រួចរាល់ |
| **៥. រៀបចំ និងបង្កើតកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍របស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | *តោះទិញ | ចំនួនសមាជិកដែលចូលរួម | ក្រុមការងារយុទ្ធសាស្ត្រ + លោកជំទាវ សូរីតា + ម្ចាស់ជំនួយ | ខែមករា ឆ្នាំ ២០២០ សម្រាប់សំណើ |
| | *ការងារខ្ញុំ (សកម្មភាពរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា និងសកម្មភាពផ្ទាល់ខ្លួនរបស់សមាជិកនៃ ស.ស.ស.ក) | ចំនួនព្រឹត្តិការណ៍ដែលបានរៀបចំ (សមាគមសហគ្រិនស្ត្រីកម្ពុជា និងព្រឹត្តិការណ៍ផ្ទាល់ខ្លួនរបស់សមាជិក) | ក្រុមការងារយុទ្ធសាស្ត្រ + លោកជំទាវ សូរីតា + ម្ចាស់ជំនួយ | ខែមករា ឆ្នាំ ២០២០ សម្រាប់សំណើ |
| | *ស្ត្រី និងអាជីវកម្ម (Women N BIZ)៖ កិច្ចសន្ទនាគ្នារយៈពេល ៣ ទៅ ៥ នាទី | ចំនួនសមាជិកសមាគមដែលបានសម្ភាសន៍ ចំនួនប្រធានបទដែលបានពិភាក្សា | ក្រុមការងារយុទ្ធសាស្ត្រ + លោកជំទាវ សូរីតា + ម្ចាស់ជំនួយ | ខែមករា ឆ្នាំ២០២០ សម្រាប់សំណើ |
| **៦. បង្កើតកម្មវិធីផ្សាយអំពីសមាគមសហគ្រិនស្ត្រីកម្ពុជាតាមវិទ្យុ** | កម្មវិធីសម្ភាសន៍តាមវិទ្យុ | ចំនួននៃការផ្សព្វផ្សាយ | អ្នកស្រីវីរីយ៉ា និងដៃគូសក្តានុពល | ត្រីមាសទី១ ខែមករា (បន្តរៀងរាល់ត្រីមាស) |

| | | | | |
|---|---|---|---|---|
| **៧. បង្កើត ឆានែល Youtube របស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | ឆានែល Youtube របស់សមាគមសហគ្រិនស្ត្រីកម្ពុជាដើម្បីបង្ហោះវីដេអូបណ្តាញសង្គមទាំងអស់ | ចំនួនវីដេអូដែលបានបង្ហោះ | អ្នកស្រីវីរីយ៉ា លោកស្រី អូនី និងលោក ផាន់ណា | ឆាប់តាមដែលអាចធ្វើទៅបាន |
| **៨. ការអប់រំ និងការបណ្តុះបណ្តាលស្តីពីការធ្វើទីផ្សារសម្រាប់សមាជិកសហគ្រិនស្ត្រីកម្ពុជា (ពាណិជ្ជកម្មអេឡិចត្រូនិកលើកម្មវិធី App)** | ជំនួយផ្នែកឌីជីថលរបស់សហគ្រាសខ្មែរចំពោះសមាគមសហគ្រិនស្ត្រីកម្ពុជាស្តីពីការពង្រឹងសមត្ថភាព | ចំនួនកម្មវិធី | សហគ្រាសខ្មែរ | ខែមករា ឆ្នាំ២០២០ |
| **៩. កាតាឡុករបស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | កាតាឡុករបស់សមាគមសហគ្រិនស្ត្រីកម្ពុជា | ចំនួនកាតាឡុកដែលបានបោះពុម្ព | លោកជំទាវ សូរីតា លោកស្រីអូនី អ្នកស្រីវីរីយ៉ា អ្នកគ្រប់គ្រងផ្នែកទីផ្សាររបស់សមាគមសហគ្រិនស្ត្រីកម្ពុជា | ខែមករា ឆ្នាំ២០២០ |
| **១០. សេចក្តីប្រកាសព័ត៌មានសន្និសីទកាសែត និងការផ្សព្វផ្សាយនៃគ្រប់ព្រឹត្តិការណ៍របស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | ការផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយទាំងអស់អំពីព្រឹត្តិការណ៍របស់សមាគមសហគ្រិនស្ត្រីកម្ពុជា | ចំនួននៃការផ្សព្វផ្សាយ ចំនួនព្រឹត្តិការណ៍ដែលបានចូលរួម | លោកជំទាវ សូរីតា វីរីយ៉ា អ្នកស្រីណៃហៀក បុគ្គលិក | រាល់ព្រឹត្តិការណ៍របស់សមាគមសហគ្រិនស្ត្រីត្រូវតែស្របគ្នាជាមួយនឹងក្រុមការងារផ្នែកប្រព័ន្ធផ្សព្វផ្សាយ |
| **១១. ព្រឹត្តិប័ត្រព័ត៌មានរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា** | បង្កើតគំរូ និងចែកចាយព្រឹត្តិប័ត្រព័ត៌មានជូនដល់សាធារណ | ចំនួននៃព្រឹត្តិប័ត្រព័ត៌មានដែលបានចែកចាយ | លោកជំទាវ សូរីតា អ្នកស្រីវីរីយ៉ា អ្នកស្រីណៃហៀក អ្នកគ្រប់គ្រងផ្នែកទីផ្សារ | មួយខែម្តង ចាប់ផ្តើមពីខែមករា ឆ្នាំ២០២០ |

| | | | | |
|---|---|---|---|---|
| | ជន និងសមាជិកសមាគម សហគ្រិនស្ត្រីកម្ពុជា | | | |
| **១២. ពិនិត្យមើលឡើងវិញ ទៅលើការបង្ហាញវត្តមាន របស់ម្ចាស់ឧបត្ថម្ភ** | ពិនិត្យលើការឧបត្ថម្ភទាំងអស់ ដើម្បីឱ្យដឹងថាយើងបាន អនុវត្តតាមអ្វីដែលបានសន្យា គ្នាសម្រាប់ការឧបត្ថម្ភ ឬទេ | ចំនួននៃម្ចាស់ឧបត្ថម្ភ នៅព្រឹត្តិការណ៍ / កម្មវិធី ផ្សេងៗគ្នា ចំនួននៃការឧបត្ថម្ភសរុប | លោកបូរិន អ្នកស្រីវីរិយ៉ា អ្នកស្រី ណៃហៀក អ្នកគ្រប់គ្រងផ្នែកទីផ្សារ លោកផាន់ណា | ពិនិត្យមើលឡើងវិញជា ប្រចាំចំពោះព្រឹត្តិការណ៍ នីមួយៗ និងរាល់ពេលដែល ទទួលថវិកា |

ឧបសម្ព័ន្ធ ១ អង្គការលេខសមាគមសហគ្រិនស្ត្រីកម្ពុជា




1.
គណៈកម្មាធិការ តស៊ូមតិ
ទីប្រឹក្សាតស៊ូមតិជាន់ខ្ពស់ (ដែលត្រូវជ្រើសរើសថ្មី)
អ្នកវិភាគ (ដែលត្រូវជ្រើសរើសថ្មី)
អ្នកតំណាងជាតិ.. (លោក យឿម ប៉ូរាន)
ជំនួយការ / អ្នកកត់កំណត់ហេតុ សម្រាប់អាស៊ាន / បណ្តាញសហគ្រិន ស្ត្រីកម្ពុជា (លោក ឡុក វិចិត្រ)
2.
គណៈកម្មាធិការ អភិវឌ្ឍអាជីវកម្ម
អ្នកគ្រប់គ្រងកម្មវិធី ពង្រឹងសមត្ថភាព (លោក ឡុក វិចិត្រ)
អ្នកគ្រប់គ្រងព្រឹត្តិការណ៍ (លោក ចាន់ សុផាន់ណា)
អ្នកសម្របសម្រួលកម្មវិធី និង ព្រឹត្តិការណ៍ (លោកស្រី សង ធារីម និងលោក ឡុក វិចិត្រ)
3.
គណៈកម្មាធិការ សមាជិកភាព
បុគ្គលបង្គោលក្នុងកម្មវិធីព្រឹត្តិការណ៍ (លោក ចាន់ សុផាន់ណា)
អ្នកសម្របសម្រួលព្រឹត្តិការណ៍ (កញ្ញា សង ធារីម)
ជំនួយការព្រឹត្តិការណ៍ (កញ្ញា ហេង ស៊ីវខេង)
4.
គណៈកម្មាធិការប្រព័ន្ធ ផ្សព្វផ្សាយ / ប្រាស្រ័យទាក់ទង
អ្នកគ្រប់គ្រងផ្នែកទីផ្សារ (លោក ធូក ពន្លឺង)
ជំនួយការបច្ចេកទេស (លោក ចាន់ សុផាន់ណា)
អ្នករៀបចំ / អ្នកសម្របសម្រួល (កញ្ញា សង ធារីម និងកញ្ញា ហេងស៊ីវខេង)

# រចនាសម្ព័ន្ធក្នុងអង្គភាព



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

| | | |
|---|---|---|
| ជូនចំពោះ | ៖ អ្នកស្រី ហ៊ុវ គីមហ៊ុច ប្រធានប្រតិបត្តិការ | M២០១៨-០០១ |
| ពី | ៖ អូនី លូណា នាយកប្រតិបត្តិ | |
| កាលបរិច្ឆេទ | ៖ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ | |
| កម្មវត្ថុ | ៖ ក្រមសីលធម៌ | |
| ចម្លងជូន | ៖ ក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មាធិការទាំងអស់ | |

ជូនចំពោះ អ្នកស្រី គីមហ៊ុច

ដើម្បីការពារសុចរិតភាព និងសេចក្តីថ្លៃថ្នូររបស់សមាគម សូមធ្វើការផ្សព្វផ្សាយឯកសារក្រមប្រតិបត្តិនេះ និងរៀបចំឱ្យបុគ្គលិក ក្រុមប្រឹក្សាភិបាល អ្នកអង្កេតក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មាធិការទាំងអស់ចុះហត្ថលេខាលើឯកសារក្រមប្រតិបត្តិដែលមានភ្ជាប់មកជាមួយនេះ។

សូមរៀបចំបកប្រែក្រមប្រតិបត្តិនេះទៅជាភាសាខ្មែរ ដោយសារតែយើងត្រូវការឱ្យមានឯកសារទាំងពីរភាសានេះសម្រាប់ប្រើប្រាស់នៅការិយាល័យរបស់យើង ឬសម្រាប់សវនកម្មអនុលោមភាព។

ឯកសារច្បាប់ដើមនឹងរក្សាទុកនៅក្នុងសំណុំឯកសារ ២០១ របស់យើង ចំណែក បុគ្គលិក ក្រុមប្រឹក្សាភិបាល អ្នកអង្កេតក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មាធិការទាំងអស់ នឹងទទួលបានឯកសារថតចម្លងសម្រាប់ជាឯកសារយោង។



ដោយក្តីរាប់អាន
អូនី លូណា
ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨



អាសយដ្ឋាន៖ ភ្នំពេញសេនធើរ អគារ G បន្ទប់លេខ ៤៨៦ (ជាន់ទី ៤) មហាវិថី សម្តេច សុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទូរសព្ទការិយាល័យ៖ (+៨៥៥) ២៣ ២២ ៤៣ ៤៦ លេខទូរសព្ទផ្ទាល់ខ្លួន៖ (+៨៥៥) ៧៨ ៩៦ ២០ ២០
អ៊ីមែល៖ info@cweacambodia.com វេបសាយត៍៖ cweacambodia.com

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

# ក្រមប្រតិបត្តិស្តីពីការរក្សាព័ត៌មានសម្ងាត់ និងទំនាស់ផលប្រយោជន៍

## សេចក្តីផ្តើម

ដើម្បីអាចបំពេញភារកិច្ច និងទំនួលខុសត្រូវជាក់លាក់មួយចំនួនសម្រាប់លើកកម្ពស់សុខុមាលភាពរបស់សមាគមរបស់យើង ក្រមប្រតិបត្តិនេះ មានលើកឡើងអំពីភារកិច្ច និងទំនួលខុសត្រូវទាំងនោះ ដោយស្របតាមឯកសារគ្រប់គ្រងសម្រាប់គ្រប់ភាគីពាក់ព័ន្ធនីមួយៗទាំងអស់របស់សមាគម ដែលមានសិទ្ធិប្រើប្រាស់ព័ត៌មានសម្ងាត់នៅក្នុងសមាគម អាចនៅក្នុងទម្រង់ជាប្រតិបត្តិការ និងកម្មវិធីជាដើម។

## I. រក្សាព័ត៌មានសម្ងាត់

សមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិក ប្រធាន និងសមាជិកគណៈកម្មាធិការ និងអ្នកអង្កេតការណ៍ក្រុមប្រឹក្សា នឹងមានសិទ្ធិចូលទៅប្រើប្រាស់ព័ត៌មាន ដែលប្រសិនបើព័ត៌មានទាំងនោះត្រូវបានបញ្ចេញទៅកាន់អ្នកខាងក្រៅ អាចនឹងបង្កឱ្យមានការខូចខាត ឬបង្កជាចំណុចរសើបដល់សមាជិក ឬបុគ្គលិកផ្សេងទៀត ប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់សមាគម ឬថែមទាំងអាចបង្កើតឱ្យមានទំនួលខុសត្រូវផ្លូវច្បាប់ថែមទៀតផង។ ព័ត៌មានដែលមានផ្តល់ជូនទៅក្រុមប្រឹក្សាភិបាល និងបុគ្គលិក អាចមានជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហាបុគ្គលិក ហិរញ្ញវត្ថុ កិច្ចសន្យា សមាជិកភាព ឬស្ថានភាពផ្លូវច្បាប់។ ជារឿយៗ ព័ត៌មាននេះ គឺជាព័ត៌មានសម្ងាត់ និងមានគោលបំណងប្រើប្រាស់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងកិច្ចការអភិបាលកិច្ចប៉ុណ្ណោះ។ ព័ត៌មាននេះ ត្រូវតែរក្សាទុកជាការសម្ងាត់បំផុត និងមិនត្រូវផ្សព្វផ្សាយទៅកាន់ភាគីខាងក្រៅណាមួយបានដឹងឡើយ រួមបញ្ចូលទាំងសមាជិកផ្សេងទៀតដែលមិនមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាភិបាល ឬនាយកប្រតិបត្តិរបស់សមាគម។



អាសយដ្ឋាន៖ ភ្នំពេញសេនធើរ អគារ G បន្ទប់លេខ ៨៨៦ (ជាន់ទី ៨) មហាវិថី សម្តេច សុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទូរសព្ទការិយាល័យ៖ (+៨៥៥) ២៣ ២២ ៨៣ ៨៦ លេខទូរសព្ទផ្ទាល់ខ្លួន៖ (+៨៥៥) ៧៨ ៩៦ ២០ ២០
អ៊ីមែល៖ info@cweacambodia.com វេបសាយត៍៖ cweacambodia.com

## II. ទំនាស់ផលប្រយោជន៍

សមាជិកនៃក្រុមប្រឹក្សាភិបាល បុគ្គលិក ប្រធាន និងសមាជិកគណៈកម្មាធិការ និងអ្នកអង្កេតការណ៍ក្រុមប្រឹក្សាភិបាល ទទួលបន្ទុកលើភារកិច្ចកម្រិតខ្ពស់ចំពោះសមាគម។ អាស្រ័យហេតុនេះ សមាជិកក្រុម បុគ្គលិក ប្រធាន និងសមាជិកគណៈកម្មាធិការ និងអ្នកអង្កេតការណ៍ក្រុមប្រឹក្សាភិបាល មិនត្រូវរក្សាសហគ្រាសអាជីវកម្មណាមួយ ឬសកម្មភាពផ្សេងៗទៀតដែលមានវិវាទដោយផ្ទាល់ជាមួយនឹងផលប្រយោជន៍របស់សមាគម ព្រមទាំងមិនត្រូវបញ្ចុះបញ្ចូលសមាជិកក្នុងហេតុផលណាមួយដែលមិនពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងអាជីវកម្មរបស់សមាគមនោះទេ។

## III. ការបំពាន

ការបំពានលើក្រមប្រតិបត្តិ អាចនឹងនាំឱ្យមានការចាត់វិធានការវិន័យ ស្របតាមឯកសារគ្រប់គ្រង។ វិធានការវិន័យអាចរួមមាន ការដកសមាជិកក្រុមប្រឹក្សាភិបាលចេញពីតំណែង ឬការបញ្ឈប់បុគ្គលិកជាដើម។

### ការទទួលស្គាល់អំពីការទទួល

ខ្ញុំសូមទទួលស្គាល់ថា ខ្ញុំពិតជាបានទទួល និងបានអានឯកសារក្រមប្រតិបត្តិនេះពិតប្រាកដមែន ហើយខ្ញុំសូមទទួលខុសត្រូវលើការអនុវត្តតាមក្រមប្រតិបត្តិនេះ។

____________________ ____________________

ហត្ថលេខា កាលបរិច្ឆេទ



អាសយដ្ឋាន៖ ភ្នំពេញសេនធើរ អគារ G បន្ទប់លេខ ៨៨៦ (ជាន់ទី ៨) មហាវិថី សម្តេច សុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទូរសព្ទការិយាល័យ៖ (+៨៥៥) ២៣ ២២ ៨៣ ៨៦
លេខទូរសព្ទផ្ទាល់ខ្លួន៖ (+៨៥៥) ៧៨ ៩៦ ២០ ២០
អ៊ីមែល៖ info@cweacambodia.com
វេបសាយត៍៖ cweacambodia.com

CWEA

សមាគមសហគ្រិនស្ត្រីកម្ពុជា

CAMBODIA WOMEN ENTREPRENEURS ASSOCIATION

# ក្រមសីលធម៌របស់សមាគមសហគ្រិនស្ត្រីកម្ពុជា

**ខ្ញុំគប្បី...**

១. ស្តាប់អ្នកដឹកនាំ ប្រធានគណៈកម្មាធិការ និងសមាជិកគណៈកម្មាធិការផ្សេងៗប្រកបដោយការយកចិត្តទុកដាក់។

២. គិតពិចារណាដោយយកចិត្តទុកដាក់ និងគោរពគំនិតរបស់មេដឹកនាំ/ប្រធានគណៈកម្មាធិការ/សមាជិកគណៈកម្មាធិការផ្សេងទៀត។

៣. គោរព និងគាំទ្រនូវគ្រប់សេចក្តីសម្រេចមតិភាគច្រើនរបស់ថ្នាក់ដឹកនាំ។

៤. ទទួលស្គាល់សិទ្ធិអំណាចដែលបានផ្ទេរឱ្យនៅក្នុងថ្នាក់ដឹកនាំ។

៥. ចូលរួមឱ្យបានសកម្មក្នុងកិច្ចប្រជុំ និងសកម្មភាពនានា ហើយមិនត្រូវធ្វើការពិភាក្សានៅកន្លែងណាផ្សេងអំពីអ្វីដែលខ្ញុំមិនមានឆន្ទៈក្នុងការពិភាក្សានៅក្នុងកិច្ចប្រជុំឡើយ។

៦. ទាញចំណាប់អារម្មណ៍ថ្នាក់ដឹកនាំរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ទៅលើបញ្ហាដែលខ្ញុំគិតថានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សមាគមសហគ្រិនស្ត្រីកម្ពុជា ឬសមាគមដែលយើងធ្វើការងារជាមួយ។

៧. ព្យាយាមលើកឡើងអំពីតម្រូវការរបស់សមាគមដែលយើងធ្វើការងារជាមួយជូនថ្នាក់ដឹកនាំ។

៨. បញ្ជូនបណ្តឹងដោយផ្ទាល់ទៅកាន់ថ្នាក់ណាមួយដែលសមស្របតាម "ច្រវាក់នៃថ្នាក់ដឹកនាំ"។

៩. ទទួលស្គាល់អំពីកិច្ចការ និងការងារលំបាក ដើម្បីធានាថាអង្គភាព ត្រូវបានគ្រប់គ្រងយ៉ាងល្អប្រសើរ មិនចាំបាច់គ្រប់គ្រងអង្គភាពនិងចៀសវាងការស្តីបន្ទោសទៅលើកំហុសអចេតនាផ្សេងៗ។

១០. តំណាងឱ្យសមាគមផ្សេងៗដែលយើងធ្វើការងារជាមួយ ធៀបនឹងក្រុមភូមិសាស្ត្រ ឬក្រុមទទួលបានប្រយោជន៍ពិសេស។

១១. ចាត់ទុកខ្លួនឯងជា "បរធនបាល" របស់អង្គភាព ហើយត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការធានាថា សមាគមមានការគ្រប់គ្រងល្អប្រសើរ មានសន្តិសុខផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការស្របទៅតាមកម្មវត្ថុដែលបានកំណត់របស់យើង។

១២. ធ្វើការងារដើម្បីសិក្សាអំពីរបៀបក្នុងការបំពេញការងារឱ្យអស់លទ្ធភាពរបស់ខ្ញុំ។

អាសយដ្ឋាន៖ ភ្នំពេញសេនធើរ អគារ G បន្ទប់លេខ ៨៨៦ (ជាន់ទី ៨) មហាវិថី សម្តេច សុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទូរសព្ទការិយាល័យ៖ (+៨៥៥) ២៣ ២២ ៨៣ ៨៦
លេខទូរសព្ទដៃ៖ (+៨៥៥) ៧៨ ៩៦ ២០ ២០
អ៊ីមែល៖ info@cweacambodia.com
វេបសាយត៍៖ cweacambodia.com

១៣. ទទួលស្គាល់នូវទំនាស់ផលប្រយោជន៍រវាងជីវិតផ្ទាល់ខ្លួន និងមុខតំណែងនៅក្នុងថ្នាក់ដឹកនាំ ហើយត្រូវចៀសវាងពីការបោះឆ្នោត ឬព្យាយាមជះឥទ្ធិពលលើបញ្ហាដែលខ្ញុំកំពុងមានទំនាស់ជាមួយ។
១៤. ពិនិត្យ និងឆ្លើយតបជាប្រចាំទៅនឹងឯកសារអេឡិចត្រូនិក និងឯកសារព្រីន ហើយ
១៥. យោងតាមបទបញ្ជាផ្ទៃក្នុងរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ខ្ញុំនឹងចូលរួមគ្រប់កិច្ចប្រជុំផ្ទាល់ និងកិច្ចប្រជុំពីចម្ងាយទាំងអស់។ ប្រសិនបើមិនអាចចូលរួមបានទេ ខ្ញុំនឹងធ្វើការជូនដំណឹងទៅកាន់ប្រធាន ឬអ្នកទទួលសិទ្ធិដោយផ្ទាល់។

**ខ្ញុំមិនគប្បី...**

១. រិះគន់សមាជិកដូចគ្នា ឬគំនិតរបស់ពួកគាត់នៅខាងក្រៅបន្ទប់នោះទេ។
២. ប្រើប្រាស់អង្គភាព ឬមុខតំណែងដើម្បីទាញជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាប្រយោជន៍សម្រាប់មិត្តភក្តិ សាច់ញាតិ ឬបក្សពួករបស់ខ្ញុំឡើយ។
៣. ប្រើប្រាស់/ចរចាទៅលើកម្មវិធី ផលិតផល ឬសេវាណាមួយដែលបានពិភាក្សាដោយថ្នាក់ដឹកនាំសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ។
៤. ពិភាក្សាដំណើការនីតិវិធីសម្ងាត់របស់ថ្នាក់ដឹកនាំនៅខាងក្រៅបន្ទប់ក្រុមប្រឹក្សានោះទេ។
៥. សន្យាថាខ្ញុំនឹងបោះឆ្នោតលើបញ្ហាណាមួយមុនពេលស្តាប់ឮការពិភាក្សា និងទទួលបានព័ត៌មានទាំងស្រុងអំពីបញ្ហានោះ។
៦. ជ្រៀតជ្រែកភារកិច្ចរបស់បុគ្គលិក ឬធ្វើឱ្យខូចខាតដល់សិទ្ធិអំណាចរបស់ប្រធានបុគ្គលិកក្នុងការអនុវត្តកិច្ចការរបស់ពួកគាត់ ហើយ
៧. និយាយក្នុងនាម ឬតាងនាមឱ្យអង្គភាព ប្រើប្រាស់ឈ្មោះ ឬរូបសញ្ញារបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ឬលើកឡើងអំពីការឧបត្ថម្ភ ឬការអនុម័តរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា លើកលែងតែមានការផ្តល់សិទ្ធិជាពិសេសឱ្យធ្វើបែបនេះ។

## ប្រការ ១១៖ ការបណ្តេញចេញ

១១.១ សមាជិកណាម្នាក់របស់សមាគមសហគ្រិនស្ត្រីកម្ពុជា ដែលបានរំលោភបំពានលើលក្ខន្តិកៈ ឬសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងមហាសន្និបាទរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា អាចនឹងត្រូវបណ្តេញចេញពីមុខតំណែងដោយក្រុមប្រឹក្សាភិបាល ហើយការបោះឆ្នោត នឹងត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំវិសាមញ្ញដែលរៀបចំឡើងសម្រាប់គោលបំណង ស្របទៅតាមលក្ខន្តិកៈរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា។

១១.២ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវធ្វើការជូនដំណឹងឱ្យបានយ៉ាងតិចណាស់ប្រាំពីរ (៧) ថ្ងៃមុនពេលដែលត្រូវបណ្តេញចេញសមាជិកណាម្នាក់ ហើយត្រូវបញ្ជាក់អំពីមូលដ្ឋានក្នុងការបណ្តេញ

ចេញផងដែរ។ សមាជិកណាម្នាក់ដែលត្រូវបានស្នើឱ្យបណ្តេញចេញ ត្រូវមានសិទ្ធិក្នុងការបង្ហាញវត្តមាននៅក្នុងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ដើម្បីធ្វើសេចក្តីថ្លែងការដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែសមាជិករូបនោះ មិនត្រូវបង្ហាញវត្តមាន ក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោតនោះទេ។ ការបោះឆ្នោត ត្រូវធ្វើឡើងដោយសម្ងាត់។

១១.៣ ការបណ្តេញចេញ [សមាជិកខាងលើ] ត្រូវតែទទួលបានការគាំទ្រពីសមាជិកចំនួនបីភាគបួន (៣/៤) នៃចំនួនសមាជិកសរុប ដែលមានវត្តមាននៅក្នុងមហាសន្និបាត។ មហាសន្និបាត អាចនឹងលុបចោល [ការបណ្តេញចេញ] បាន ដោយផ្អែកលើមូលដ្ឋាន [របស់ខ្លួន] ស្របទៅតាមកាលៈទេសៈនៃស្ថានភាពជាក់លាក់។

១១.៤ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវអនុលោមតាមលក្ខន្តិកៈ និងវិធាននៃនីតិវិធីនៃការបណ្តេញចេញ។

១១.៥ សមាជិក អាចនឹងត្រូវបណ្តេញចេញដោយស្វ័យប្រវត្តិ ក្នុងករណីដែលពួកគាត់ខកខានមិនបានបង់ភាគទានសមាជិកភាពរយៈពេលពីរឆ្នាំជាប់គ្នា ហើយការបង់លើកចុងក្រោយមិនត្រូវធ្វើឡើងយឺតជារយៈពេលហុកសិប (៦០) ថ្ងៃនោះទេ។

## **ប្រការ ១២៖ មូលដ្ឋានសម្រាប់ការបណ្តេញចេញ**

១២.១ សមាជិករបស់សមាគមសហគ្រិនស្ត្រីកម្ពុជា នឹងត្រូវបណ្តេញចេញក្នុងករណីដែលបានរំលោភបំពានលើ ឬល្មើសទៅនឹងលក្ខន្តិកៈ ឬប្រព្រឹត្តសកម្មភាពណាមួយដែលនាំឱ្យមានការខូចខាតដល់កិត្តិយសរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា។

- ខ) សមាជិកណាម្នាក់ ដែលផ្សព្វផ្សាយអំពីព័ត៌មានមិនពិតដែលនាំឱ្យខូចខាតដល់គុណតម្លៃរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ឬបញ្ចេញព័ត៌មានសម្ងាត់។
- គ) សមាជិកណាម្នាក់ដែលបង្ហាញអត្តសញ្ញាណខ្លួនឯងថា បំពេញការងារតាងនាមឱ្យសមាគមសហគ្រិនស្ត្រីកម្ពុជា ដោយមិនមានការចាត់តាំងដោយក្រុមប្រឹក្សាភិបាល។

១២.២ សមាជិក ត្រូវមានសិទ្ធិក្នុងការស្នើសុំលាឈប់ពីសមាគមសហគ្រិនស្ត្រីកម្ពុជា តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ សុពលភាពនៃសមាជិកភាព ត្រូវតែផុតកំណត់ នៅពេលដែលមានការអនុម័តដោយក្រុមប្រឹក្សាភិបាលជាលាយលក្ខណ៍អក្សរនៅលើលិខិតលាឈប់ នៅក្នុងកិច្ចប្រជុំដំបូងរបស់ខ្លួន ឬនៅពេលទទួលបានលិខិតលាឈប់នោះ។

ខ្ញុំបានអានប្រកបដោយការយកចិត្តទុកដាក់ និងយល់ច្បាស់អំពីសេចក្តីថ្លែងខាងលើ ហើយខ្ញុំសូមផ្តិតស្នាមមេដៃដើម្បីបញ្ជាក់អំពីការយល់ដឹងរបស់ខ្ញុំ។

ឈ្មោះជាអក្សរពុម្ព និងហត្ថលេខា៖_______________________ កាលបរិច្ឆេទ៖__________

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

## គោលការណ៍ណែនាំអំពីការប្រើប្រាស់ប្រអប់សារ - គណៈកម្មាធិការអភិវឌ្ឍន៍អាជីវកម្ម

ឈ្មោះគណៈកម្មាធិការ៖ អភិវឌ្ឍន៍អាជីវកម្ម ដោយលោកជំទាវ ម៉ម ដាគ្គាលីណែត
អនុគណៈកម្មាធិការ៖

(១) ផ្នែកពង្រឹងសមត្ថភាព - លោកស្រី យូ បូរី
(២) ផ្នែកបណ្តាញអាជីវកម្ម - លោកស្រី លឹម វីរីយ៉ា
(៣) អនុគណៈកម្មាធិការនវានុវត្តន៍ - លោកស្រី គ្រីស្ទីន ហ្គោធៀរ

### (១) ប្រអប់សារ Facebook

ប្រអប់សារនេះត្រូវបានណែនាំឱ្យប្រើសម្រាប់រាល់ការទំនាក់ទំនងទាំងអស់ពាក់ព័ន្ធនឹងការិយាល័យ ដោយសារតែឯកសារភាគច្រើន ត្រូវបានបង្កើតឡើងចេញពីកុំព្យូទ័រ មិនមែនចេញពីទូរសព្ទដៃនោះទេ។

ដោយសារតែនៅក្នុងកុំព្យូទ័រ មិនមានកម្មវិធី Telegram ដូច្នេះ យើងសូមផ្តល់ការណែនាំជាផ្លូវការអំពីការប្រាស់ប្រព័ន្ធបណ្តាញសង្គមដូចខាងក្រោម។

ក. ប្រអប់សារសម្រាប់គណៈកម្មាធិការអភិវឌ្ឍន៍អាជីវកម្ម៖

- ក. សម្រាប់តែប្រធានក្រុមប្រឹក្សាភិបាលប្រើប្រាស់ នៅពេលគាត់ចង់ទាញចំណាប់អារម្មណ៍របស់អនុគណៈកម្មាធិការទាំងមូលតែប៉ុណ្ណោះ។ មានតែប្រធានបទរបស់អនុគណៈកម្មាធិការនេះប៉ុណ្ណោះដែលត្រូវទាញយកចំណាប់អារម្មណ៍ និង ឬសម្រាប់ការបញ្ចេញមតិរួម និងការស្នើសុំពីអនុគណៈកម្មាធិការនីមួយៗ។

ខ. អនុគណៈកម្មាធិការនវានុវត្តន៍

- ក. គប្បីប្រើប្រាស់សម្រាប់កម្មវិធីជាក់លាក់ណាមួយដែលដំណើរការដោយអនុគណៈកម្មាធិការនវានុវត្តន៍។

គ. អនុគណៈកម្មាធិការបណ្តាញអាជីវកម្ម៖

ទីតាំងការិយាល័យ ស.ស.ស.ក ៖ អគារភ្នំពេញសិនធើរ បន្ទប់ ៨៨៦ មហាវិថីសុធារស កែងមហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា លេខទូរសព្ទ +៨៥៥ ២៣ ២២ ៨៣៨៦
+៨៥៥ ៧៨ ៩៦ ២០២០

ក. គប្បីប្រើប្រាស់សម្រាប់កម្មវិធីជាក់លាក់ណាមួយដែលដំណើរការដោយអនុគណៈកម្មាធិការបណ្ដាញធុរកិច្ច។

ឃ. ប្រអប់សារអនុគណៈកម្មាធិការពង្រឹងសមត្ថភាព

គប្បីប្រើប្រាស់សម្រាប់កម្មវិធីជាក់លាក់ណាមួយដែលដំណើរការដោយអនុគណៈកម្មាធិការពង្រឹងសមត្ថភាព។

រាល់ការបញ្ជូនប្រធានបទ វាគ្មិន និង ឬសកម្មភាពជាក់លាក់ណាមួយពាក់ព័ន្ធនឹងអនុគណៈកម្មាធិការ ត្រូវតែទទួលបានការអនុម័ត ដើម្បីដាក់ជូនគណៈកម្មាធិការជាក់លាក់ណាមួយពិនិត្យ និងចុះហត្ថលេខាលើសកម្មភាព និងកម្មវិធីដែលបានណែនាំ។

**(២) កម្មវិធី Telegram**

កម្មវិធី Telegram ត្រូវបានប្រើប្រាស់ជាប្រព័ន្ធបញ្ជូនឆាប់រហ័សក្នុងការប្រាស្រ័យទាក់ទងគ្នា ប៉ុន្តែនៅក្នុងបរិបទមួយចំនួន កម្មវិធីនេះមិនអាចអាប់ឡូតចូលទៅក្នុងកុំព្យូទ័របានទេ ហើយអាចប្រើប្រាស់បានតែតាមទូរសព្ទដៃតែប៉ុណ្ណោះ។

ដូច្នេះ កម្មវិធី Telegram អាចប្រើប្រាស់ជាផ្លូវការសម្រាប់តែក្នុងករណីពិសេសមួយចំនួនដូចជាការអាប់ឡូតរូបថត ការហៅទូរសព្ទ និងការផ្ញើសារជាអក្សរ និងឬសម្រាប់ការទូរសព្ទជាក្រុមតែប៉ុណ្ណោះ ប៉ុន្តែសូមកាត់បន្ថយការប្រើប្រាស់កម្មវិធីនេះឱ្យបានតិចតួចតាមតែអាចធ្វើទៅបាន ហើយប្រើប្រាស់តែក្នុងពេលមានបន្ទាន់តែប៉ុណ្ណោះ ដោយសារតែមុខងាររបស់កម្មវិធីនេះ គឺដូចគ្នាទៅនឹងកម្មវិធី Facebook ដែរ។

ចំណុចនេះត្រូវបានអនុវត្ត ដើម្បីរក្សាការប្រាស្រ័យទាក់ទងឱ្យបានល្អ និងអាចស្វែងរកបានដោយមិនមានភាពភាន់ច្រលំ។

ក. Group Telegram (BD) - សម្រាប់ប្រើប្រាស់តែក្នុងពេលចាំបាច់ម្ដងម្កាលតែប៉ុណ្ណោះ។

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

## គោលការណ៍ណែនាំអំពី "ការលើកលែងថ្លៃសេវាវិភាគទាន" សិក្ខាសាលាបង់ថ្លៃ និងមិនមានការឧបត្ថម្ភ

ឈ្មោះគណៈកម្មាធិការ៖ អភិវឌ្ឍន៍អាជីវកម្ម ដោយលោកជំទាវ ម៉ម ដាត្លាលីណែត
អនុគណៈកម្មាធិការ៖ អនុគណៈកម្មាធិការបណ្ដាញអាជីវកម្ម

សិក្ខាសាលា និងបណ្ដាញអាជីវកម្ម ត្រូវបានរចនាឡើងសម្រាប់សមាជិក និងអ្នកមិនមែនសមាជិក ស.ស.ស.ក ដែលមានបំណងសិក្សាក្នុងកម្មវិធីដែលបានផ្ដល់ជូនដោយគណៈកម្មាធិការនេះ។ ដូច្នេះ ការគិតថ្លៃសេវា គឺនឹងត្រូវអនុវត្តចំពោះអ្នកចូលរួមដែលមានបំណងសិក្សា និងអ្នកចូលរួមជាសិស្ស។ ដូច្នេះ សម្រាប់អ្នកដែលមកចូលរួម ដែលមិនមែនមកសិក្សារៀនសូត្រ ប៉ុន្តែជាអ្នកសម្របសម្រួល និងធ្វើការងារ គឺមិនត្រូវបានគិតថ្លៃសេវានោះទេ។

ក្នុងករណីដែលមានអ្នកចូលរួមខ្លះ គ្រាន់តែជាអ្នកមកអមវាគ្មិន និងមិនមែនជាអ្នកចូលរួមសិក្សា ដូច្នេះអ្នកទាំងនោះក៏មិនគិតថ្លៃសេវាដែរ។

### (១) ឥតគិតថ្លៃ

ក) ប្រធាន
ខ) អ្នកសម្របសម្រួល/គណៈកម្មាធិការពាក់ព័ន្ធ និងអនុគណៈកម្មាធិការអនុវត្ត
គ) វាគ្មិន និងភ្ញៀវដែលមាននៅក្នុងរបៀបវារៈ
ឃ) ពិធីករ
ង) អ្នករៀបចំកម្មវិធី / បុគ្គលិក
ច) អ្នកអមដំណើរវាគ្មិន

### (២) បង់តាមការចំណាយ

ក) អនុគណៈកម្មាធិការដែលស្ថិតក្នុងក្រុមគណៈកម្មាធិការដូចគ្នា ដោយសារតែពួកគាត់បានចូលរួមក្នុងការរៀបចំផែនការ និងបង្កើតគំនិតនានាលើសិក្ខាសាលានេះ។
ខ) សមាជិកអនុគណៈកម្មាធិការ

**៣) បង់ពេញថ្លៃ**

ការចូលរួមរបស់សមាជិក ស.ស.ស.ក ទៅតាមតម្លៃដែលបានកំណត់ដោយអ្នករៀបចំកម្មវិធី។

ការចូលរួមរបស់អ្នកមិនមែនជាសមាជិក ស.ស.ស.ក ទៅតាមតម្លៃដែលបានកំណត់ដោយអ្នករៀបចំកម្មវិធី។